# ទស្សនាវដ្តី
# សាស្ត្រាចារ្យ

G·305/370/597/A

ROYAUME DU CAMBODGE
REGIE DU DEPOT LEGAL

ផ្សាយចេញ
រាល់ត្រីមាស
ពី

សមាគម
សាស្ត្រាចារ្យខ្មែរ

ទីស្នាក់ការ
លេខ ១២៣ E វិថីព្រះសីហនុ ភ្នំពេញ



កក្កដា - សីហា - កញ្ញា - តុលា - វិច្ឆិកា - ធ្នូ

ឆ្នាំ ទី ៦

លេខ
19

## មាតិការឿង :


- ចិត្ត-គរុកោសល្យ
  - Où en est la réforme de l'enseignement ? 1
  - ស្នាដៃថ្មី លើរណសិរ្សសិក្សាធិការ នៅប្រទេសចិន 4
  - កំណាព្យ : ខ្ញុំសាងជីវភាព — ម៉ម បន្ធា 9
- ការទាក់ទងរបស់ ស.ស.ខ. 11
- ពិធីទទួលសៀវភៅអំពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ 16
  - សុន្ទរកថារបស់ ម. លាង ហាប់អាន អគ្គលេខាធិការ វ.ព.ស.
  - សុន្ទរកថារបស់ ម មាស ឌឹម ប្រធាន ស.ស.១.
- ស្នូរជួងសាលា 24
- មហាសន្និបាតសាមញ្ញ ស.ស.ខ. 1965 28
  - សេចក្ដីរាយការណ៍សកម្មភាព — ទីវ អុល អគ្គលេខាធិការ
  - សេចក្ដីរាយការណ៍ ហិរញ្ញវត្ថុ — ឡឹក វ៉ែន អគ្គហេរញ្ញិក
- ពិធីជប់លៀងនឹងដំណើរកំសាន្ត 44
- ដំណឹងខ្លី ៗ 49
- អត្ថបទនឹងឯកសារ
  - ការប្រែប្រួលអាស៊ី អាហ្វ្រិក 1955 — 1965 52
  - វិញ្ញាសាប្រឡង 55
  - ប្រវត្តិវិទ្យា — ម៉ៃ លន់ អគ្គលេខាធិការ ស. ប. ស. ១. 62
  - វេយ្យាករណ៍ — ញ៉ឹប ម៉ៅ សាស្ត្រាចារ្យ មហាវិ-គរុ 68
  - អត្ថបទអនុពាក្យ 72

R. le 9-2-66



# OU EN EST LA REFORME DE L'ENSEIGNEMENT ?

On entend beaucoup parler de réduction de durée d'études dans le cycle secondaire, de refonte du programme, de la suppression du Baccalauréat 1ère partie etc ... Finalement, la rentrée scolaire s'est faite sans qu'une modification spectaculaire soit intervenue. Y a-t-il réellement une réforme de l'enseignement en vue ?

Selon nos renseignements recueillis auprès des sources proches du Ministère de l'Education Nationale, voici où en est cette réforme, dans le cas de l'Enseignement Secondaire.

**I.— Y aura-t-il une réduction de durée d'études ?**

Oui, d'après les avis formulés par les professeurs et responsables des établissements de la capitale au cours d'une réunion tenue le 2 Septembre 1965, le système suivant a été proposé

— 4 années d'études dans le 1er cycle
— 2 années d'études dans le 2e cycle

En tout, 6 années d'études secondaires, au lieu de 7.

**II.— Le Baccalauréat National 1ère partie sera-t-il supprimé ?**

Selon la décision du Conseil Supérieur de l'Education, les deux Baccalauréats actuels seront remplacés par un seul Baccalauréat National qui sanctionnera le fin des études secondaires. La réunion précédente des responsables et professeurs est du même avis. Cette décision entrera en vigueur en 1966.

**III.— Dans quel sens se fera la réforme du programme ?**

Plusieurs idées président à cette réforme.

D'abord les vœux exprimés par Samdech chef de l'Etat au cours d'une réunion de travail : écouter la durée d'études, simplifier les barrières des examens pour pourvoir nos Universités nouvellement créées; spécialisation des études secondaires dans des sections A, B, C,... pour que nos jeunes soient plus aptes à choisir un métier, au lieu de recevoir un enseignement d'un caractère trop général qui en ferait de semi-intellectuels inutilisables sur le plan professionnel .

Compte-tenu des hautes instructions de Samdech chef de l'Etat, les responsables ( Conseil Supérieur de l'Education. Commission Technique du Programme ) se fixent en outre pour principe de :

* maintenir le niveau actuel; la réduction de la durée d'études ne doit pas entraîner une nouvelle baisse de niveau;

* harmoniser le programme entre les différentes années d'études, d'où la nécessité de tout remanier depuis la classe de 6e jusqu'à la classe de 1ère, et ceci dans chaque section, à cause de l'interdépendance des disciplines (ex: Mathématiques et Physiques doivent concorder);

* spécialiser dans le sens d'orienter selon la vocation des élèves, mais non spécialiser à fond comme dans les écoles professionnelles. Les conditions des collèges et lycées du royaume ne se prêtent pas à une transformation aussi radicale. D'ailleurs l'enseignement secondaire ne doit pas être confondu avec l'enseignement professionnel et technique.

Finalement, il a été proposé dans la Commission Technique du Programme de laisser aux classes de 6e et 5e leur caractère d'enseignement général. A partir de la classe de 4e, les élèves auraient à choisir entre les trois sections suivantes :

1·/ **Section A** : Sciences humaines (enseignement où prédominent les lettres khmères, les lettres françaises, la philosophie, les langues vivantes, l'histoire et la géographie).

2·/ **Section B** : Sciences technico-mathématiques (enseignement où prédominent les mathématiques, la physique, la technologie).

3·/ **Section C** : Sciences agronomiques et expérimentales (enseignement où prédominent la physique, la chimie, les sciences naturelles, les sciences agricoles).

A la fin de la classe de 1ère, chaque section est sanctionnée par un Baccalauréat correspondant (serie A.B.C). Les débouchés probables pour chaque section pourraient être les suivants :

**Section A** : Faculté de Droit; Université des Beaux-Arts; Faculté des Lettres; Sciences commerciales; banques; Professorat de Lettres Khmères ou Françaises, de langues vivantes, de philosophie, d'histoire-géographie; rédacteurs; interprêtes; chefs d'entreprise; conservateurs etc . . .

**Section B** : Facultés des Sciences; Ecoles d'Ingénieurs (T.P; électricité, hydraulique, arts et métiers, architecture et urbanisme); carrières de l'industrie; recherche; Ecoles d'Officiers. Professorat de Math.

**Section C** : Faculté des Sciences; Faculté de Médecine et annexes, Faculté de Pharmacie; Ecoles d'Ingénieurs agricoles et de Vétérinaires; Ecoles de Chimie; Faculté de Cultures tropicales; Faculté d'Electrotechnique; Professorat de Sciences physiques ou de Sciences naturelles. etc. . . .

**IV.— Et le Diplôme d'Etudes Secondaires du 1er Cycle sera-t-il maintenu ?**

Le D. E. S. P. C. reste une étape pour ceux qui ne peuvent aller jusqu'au bout des années d'études secondaires. Il y aura à prévoir un programme d'enseignement court pour le 1er cycle de 4 ans, de façon que dans chaque section les élèves reçoivent un enseignement assez complet. Le 2e cycle de 2 ans complètera le 1er cycle par un enseignement qui serait « intermédiaire entre l'enseignement long et l'enseignement court» comme disent les spécialistes. Comme pour le Baccalauréat, le D. E. S P. C. comptera les séries A.B. C. Les titulaires pourraient embrasser une carrière ou s'orienter vers les écoles d'apprentissage ou professionnelles.

Telles sont à peu près les grandes lignes de cette réforme dont la mise en application serait prévue pour la rentrée de Septembre 1966, si tout marche bien . Actuellement, des commissions techniques se partagent les disciplines, pour élaborer le nouveau programme. C'est le plus gros morceau à avaler. La tâche sera ardue, mais il faut faire vite et, à notre avis, ne pas perdre de vue les moyens d'application à la disposition des responsables. Nous tiendrons nos membres au courant de ce qui sera fait et acquis dans notre prochain numéro. Cette réforme dans l'Enseignement Secondaire n'est qu'un aspect d'une réforme plus vaste qui touche également l'Enseignement Primaire et l'Enseignement Supérieur.

# ស្នាដៃថ្មីលើរណសិរ្សសិក្សាធិការ

សិក្សាធិការ ដែលបង្គាប់ការសិក្សាជាមួយនឹងការងារឧស្សាហកម្ម ឬ ជាមួយនឹងការងារកសិកម្ម គឺជាប្រព័ន្ធថ្មីមួយដែលបានបង្កើតឡើងជាការសាកល្បង តាំងតែពីឆ្នាំ ១៩៥៨ មកម្ល៉េះ តាមគោលការណ៍ដែលថា សិក្សាធិការត្រូវបំរើនយោបាយនៃវណ្ណៈអធន ហើយត្រូវជាប់ទាក់ទងនឹងការងារផលិតកម្ម ។ សព្វថ្ងៃនេះ គេប្រទះឃើញសាលាដែលរៀនតែពាក់កណ្ដាលពេល (écoles à mi-temps) នៅគ្រប់តែទីក្រុងនឹងទីជនបទ ។ ទីក្រុងទាំងអស់សុទ្ធតែមានសាលាមធ្យមសិក្សាកសិកម្ម ហើយនឹងសាលាមធ្យមសិក្សាតិកនិកគ្រប់ប្រភេទ ដែលរៀនតែពាក់កណ្ដាលពេល ។ រីឯទីជនបទវិញក៏មានសាលាបឋមសិក្សាជនបទរៀនពាក់កណ្ដាលពេល សាលាមធ្យមសិក្សាកសិកម្ម ហើយនឹងសាលាមធ្យមសិក្សាតិកនិក ដែលតម្រូវឲ្យធ្វើការសិក្សាផងធ្វើការងារស្រែចំការផងដែរ ។

បន្ទាប់ពីពិសោធអស់ពេល ៦ ឆ្នាំមក ឃើញថាប្រព័ន្ធសិក្សាបែបថ្មីនេះកាន់តែបានភ្ជាប់ការសិក្សាទៅនឹងការងារផលិតកម្មច្បាស់លាស់ឡើង ៗ ហើយ ។ ប្រព័ន្ធសិក្សាបែបថ្មីនេះ បានធ្វើឲ្យការអប់រំសង្គមនិយមបំរើនលូតលាស់ឡើងតាមគោលការណ៍ "បរិមាណ-ល្បឿនលឿន-គុណភាពនឹងសន្សំសំចៃ" ។ សាលារៀនបែបថ្មីនេះបានជួយឧបត្ថម្ភបុត្របុត្រានៃជាងនឹងអ្នកស្រែចំការឲ្យបានទៅរៀនសូត្រគ្រប់ៗគ្នា ។

ក្នុងស្រែចំការ គេបានបង្កើតសាលាបឋមសិក្សាដែលបញ្ចូលការសិក្សានឹងការងារស្រែចំការជាមួយគ្នាតាមរូបភាពផ្សេងៗ ក្នុងគោលបំណងនឹងផ្ដល់នូវការងាយស្រួលដល់កសិករទាំងឡាយ ដែលចង់បញ្ជូនកូនទៅសាលារៀន ។ សិស្សអាចនឹងរៀនពាក់កណ្ដាលថ្ងៃបាន បើគេមិនអាចនឹងនៅក្នុងសាលាពេញមួយថ្ងៃបានទេ ។ ចំពោះសិស្សប្រភេទណាដែលយល់ថា ពេលពាក់

# នៅប្រទេសចិន

កណ្ដាលថ្ងៃនៅតែយូរពេកទៀតនោះ គេបង្រៀនតែពេលព្រឹក ឬនៅពេលថ្ងៃត្រង់ ឬតែពេលល្ងាចប៉ុណ្ណោះ ។ រីឯម៉ោងរៀនប្រែប្រួលជាដរាប ។ គេបង្រៀនគ្រប់ម៉ោងទាំងអស់ តាមតែសិស្សមកដល់សាលា នៅពេលព្រឹក ពេលថ្ងៃ ឬពេលល្ងាច ។ នៅក្នុងតំបន់ដែលអ្នកស្រុកស្ថិតនៅរប៉ាត់រប៉ាយ ឬចួនកាលដោយមានភ្នំ ឬផ្លូវទឹកខណ្ឌឲ្យដាច់ពីគ្នា — ជាហេតុនាំឲ្យសិស្សមានការលំបាកនឹងមកសាលា — គេក៏បានបង្កើតនូវសាលាគោចរ ។ តំបន់ចិញ្ចឹមសត្វក៏មានសាលារបស់គេដែរ: សាស្ត្រាចារ្យជិះសេះតាមបង្រៀនអ្នកចិញ្ចឹមសត្វពីកន្លែងមួយទៅកន្លែងមួយ ។ ចំពោះកូនចៅរបស់គ្រួសារដែលរស់នៅលើទឹក គេបានបង្កើតសាលាចល័តដែលស្របទៅនឹងលក្ខណៈជីវភាពរបស់អ្នកស្រុក ។ ដោយហេតុនេះហើយបានជាសិស្សកូនអ្នកទីទាល់ក្រនឹងអ្នកមធ្យមក្នុងស្រទាប់ក្រោមបំផុត បានកើនចំនួនឡើងយ៉ាងសន្ធឹកសន្ធាប់ ។ នៅឃុំជាច្រើនជាង ៩០% នៃក្មេងដែលដល់អាយុរៀនសុទ្ធតែបានចូលសាលារៀនទាំងអស់ ។

នៅទីក្រុង ការសិក្សាជាសាកល បានត្រូវសំរេចបានជាស្រេច ក្នុងបឋមសិក្សា ។ សិស្សភាគច្រើន ដែលចេញពីបឋមសិក្សាអាចបន្តការសិក្សារបស់ខ្លួននៅមធ្យមសិក្សា។ ទីក្រុងជាច្រើនបានបង្កើតនូវសាលាមធ្យមសិក្សាឧស្សាហកម្ម ដើម្បីនឹងអនុញ្ញាតឲ្យសិស្សទាំងជំនាន់ៗ ណាដែលពុំអាចបន្តការសិក្សាក្នុងសាលាមធ្យមសិក្សាពេញពេលបាន បានសិក្សាបណ្ដើរ ធ្វើការបណ្ដើរ ។

ជាមួយនឹងការធ្វើឲ្យទំនើបជាលំដាប់ (modernisation progressive) នៃឧស្សាហកម្ម នឹង កសិកម្ម ទីក្រុងនឹងស្រែចំការទាំងឡាយ ត្រូវការនូវចំនួនកាន់តែច្រើនឡើងៗ នៃអ្នកក្របខណ្ឌរដ្ឋបាល ដែលចេះគិតគិត ហើយនឹងអ្នកឯកទេស ក្នុងវិស័យផ្សេងៗ ។ ហេតុនេះ សិស្សដែលចេញពីសាលារៀន

ពាក់កណ្ដាលពេល ហើយដែលបានទៅធ្វើការក្នុងរោងចក្រ ភាគច្រើនក៏បានក្លាយទៅជាជាងយ៉ាងចំណាប់ ៗ សិស្សខ្លះបានធ្វើការជាអ្នកតិកនិក ហើយជួនកាលទទួលមុខងារជានាយរោងជាង ឬធ្វើជាបុគ្គលិករដ្ឋបាល ក្រោយពេលមានជោគជ័យក្នុងការប្រឡង ។ សិស្សជាច្រើននៃសាលាមធ្យមសិក្សាកសិកម្ម បានកាន់កាប់មុខងារជានាយក្រុមផលិតកម្ម ជាអ្នកកត់ត្រាបញ្ជីការងារប្រចាំថ្ងៃ ជាឆ្មាំឃ្លាំង ជាអ្នកបើកត្រាក់ទ័រ ជាអ្នកកាន់គ្រឿងបូមទឹក ជាអ្នកបច្ចេកកសិកម្ម (agrotechnicien) ជាគិលា-នុបដ្ឋាក ជាអ្នកអគ្គិសនី ជាពេទ្យសត្វ ជាអ្នកចិញ្ចឹមសត្វ ។ល។

គឺមកពីគេរៀនផង ធ្វើការផង ដូច្នេះបានជាសិស្សនៃសាលាមធ្យម-ឧត្ដមសិក្សារៀនពាក់កណ្ដាលពេលទាំងឡាយ មិនចាំបាច់រង់ចាំពេលចប់ការសិក្សា ដើម្បីធ្វើខ្លួនឲ្យជំនាញប៉ុក្នុងការងារទេ ។ តាំងពីក្នុងសាលាម៉្លេះ គេបានក្លាយខ្លួនជាកម្លាំងថ្មីនៃផលិតកម្មស្រេចទៅហើយ ។

ជាឧទាហរណ៍ សាលាមធ្យមសិក្សាខ្លះ បានធ្វើឲ្យដីកំរិលក្លាយទៅជាស្រែផ្ដល់ផលយ៉ាងខ្ពស់ ពីព្រោះគេបានបញ្ចូលនូវវិធីស្សង្សទៅក្នុងការធ្វើស្រែចំការ ។ សិស្សខ្លះបានផ្ដល់ដល់ក្រុមចិញ្ចឹមសត្វ នូវសត្វពូជល្អ ៗ ដែលកាន់តែកើនចំនួនរីកធំឡើង ៗ ក្រោមការថែទាំរបស់គេ ។ សិស្សខ្លះទៀតបានផ្ដល់ដំបូន្មានតិកនិក ដើម្បីការពារដើមឈើទប់ទល់នឹងជម្ងឺ ហើយនិងសត្វចង្រៃផ្សេង ៗ ជានាំឲ្យផលបានសម្បូរណ៍នៅលើផ្ទៃដីដ៏ធំទូលាយ ។

នៅក្នុងសាលារៀនពាក់កណ្ដាលពេលនៃទីក្រុង ការសិក្សាសុទ្ធៗនឹងការងារ បានដណ្ដើមរៀង ៗ ខ្លួន នូវពេលពាក់កណ្ដាលថ្ងៃម្នាក់ ឬពេញមួយថ្ងៃពេញម្នាក់ ឬមួយអាទិត្យពេញម្នាក់ ទៅតាមករណីផ្សេងៗ ។ ក្រោយពេលអប់រំគ្រប់សព្វហើយ សិស្សអាចនឹងបំពេញការងាររបស់ជាងធម្មតាបាន ។ នៅក្នុងរោងជាង គេឃើញសិស្សទាំងឡាយ បញ្ជាម៉ាស៊ីនបានយ៉ាងស្រណុកដូចជាជាងមែនទែន ឬក៏ដោះស្រាយយ៉ាង

មិនប្រសប់នូវចំណោទតិកនិក ដូចជាអ្នកតិកនិកពិតប្រាកដដែរ ។ ហេតុនេះហើយបានជានៅក្នុងពេលចក្រជ្រលក់កំណាត់សំពត់នៅ យ៉ាំងពូ (Yangpu) នាក្រុងសាំងហៃ ពេលជាងខាងសិតអំបោះ ត្រូវពិនិត្យមើលការខុសត្រូវជាញឹកញយ តែដោយជាងជំនាញការម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ ។ រីឯការងារផ្សេងៗ សុទ្ធតែត្រូវប្រគល់ឲ្យសិស្សសាលាតិកនិករៀនពាក់កណ្ដាលពេល ដែលជាសាលាស្ថិតនៅក្នុងពេលចក្រនោះតែម្ដងទាំងអស់ ។

ការបង្កើតសាលាបែបថ្មីនេះ អាចឲ្យគេអនុវត្តបានយ៉ាងងាយស្រួលនូវមូលភាព "ល្បឿនលឿន និង សន្សំសំចៃ" ក្នុងការស្ថាបនាស្រុកទេស និងការពង្រីកសិក្សាធិការ—ជាហេតុអាចបន្ថយបន្ទុកហិរញ្ញវត្ថុផ្សេងៗនៃរដ្ឋ និងនៃមហាជន ។ នៅក្នុងតំបន់ជនបទនានា សាលារៀនពាក់កណ្ដាលពេលជាច្រើនត្រូវបានកសាងចាប់តាំងពីលេខសូន្យឡើងទៅ ដោយស្នាដៃផ្ទាល់របស់សាស្ត្រាចារ្យនិងសិស្ស ដែលបានយកចិត្តទុកដាក់និងការងារក្នុងលក្ខខណ្ឌនៃមធ្យោបាយដែលគេមាន ។ គេបង្កើតខ្លួនគេផ្ទាល់នូវសម្ភារៈសិក្សា; គេធ្វើតុ កៅអី ហើយសង់បន្ទប់រៀនដោយប្រើប្រាស់របស់ដែលមាននៅនឹងកន្លែង ហើយដោយផ្ទាល់ខ្លួនគេថែមទៀត ។

ដូច្នេះ បើតាមលេខច្បាស់លាស់ ការអប់រំសិស្សម្នាក់ក្នុងសាលាមធ្យមសិក្សាតិកនិករៀនពាក់កណ្ដាលពេល អាចធ្វើឲ្យរដ្ឋសន្សំប្រាក់បានពាក់កណ្ដាលចំនួនប្រាក់ដែលត្រូវចំណាយ ដើម្បីការអប់រំសិស្សម្នាក់ក្នុងសាលារៀនពេញពេល ថ្នាក់ស្មើគ្នា និងថ្នាក់នៃសាលារៀនពាក់កណ្ដាលពេល ។ មិនតែប៉ុណ្ណោះ សិស្សនៃសាលារៀនបែបថ្មី បានបង្កើតសម្បត្តិដ៏សំបើម ឲ្យរដ្ឋដោយសារការងារបង្កើតផលរបស់គេក្នុងពេលសិក្សាថែមទៀត ។

ក៏ប៉ុន្តែ រឿងសំខាន់ក្រៃលែងនោះ គឺការដែលសាលារៀនបែបថ្មីនេះ ពុំបានផ្ដាច់ខ្លួនចេញពីផលិតកម្ម ពីតថភាព (réalité) ពីមហាជនឡើយ ។ សិស្ស-សាស្ត្រាចារ្យរៀននឹងបង្រៀនផង ហើយជ្រមុជក្បាលក្នុងការងារឧស្សាហកម្ម-កសិកម្មផង ។

សិស្សដែលត្រូវអប់រំក្នុងលក្ខណៈបែបនេះ មានសម្បទាគ្រប់គ្រាន់ក្នុងបញ្ញាកម្ម ក៏ដូចជាក្នុងហត្ថកម្ម ។ គេទាំងឡាយអាចធ្វើដំណើរទៅដល់កំរិតខ្ពង់ខ្ពស់ ទាំងខាងផ្នែកសម្បជញ្ញៈនយោបាយ ទាំងខាងផ្នែកពុទ្ធិវិទ្យា និងវប្បធម៌ ។

សាលារៀនពាក់កណ្ដាលពេល បានក្លាយជាវត្ថុនៃការសរសើរជាទូទៅពីមហាជន ។ ជាឧទាហរណ៍ នៅក្នុងឃុំលិនស៊ី ( Lintse ) ខេត្ត ចាន់តុង ( Chantong ) កសិករទាំងឡាយ បានឃើញក្នុងរូបសិស្សមានសញ្ញាប័ត្រនៃសាលាបែបនេះ នូវអ្នកធ្វើការងារមែនៗ ។ អ្នកស្រុកបានប្រកាសថា: „ សិស្សទាំងនេះ គេមានទម្លាប់នឹងការងារ គេមិនខ្លាចហត់ មិនខ្លាចប្រឡាក់ ហើយគេប្រគល់ខ្លួនដោយរីករាយ ឲ្យការធ្វើស្រែចំការ „ ។ យុវជនក្មេង ៗ ចេះដឹង ហើយឈ្លាសវៃក្នុងរឿងតិកនិក ដែលជាអ្នកចេះធ្វើការល្អដោយដៃក៏បាន ដោយខួរក្បាលក៏បាន ទាំងនេះ មានសមត្ថភាពនឹងបំពេញកិច្ចការរបស់គេបានគ្រប់ទីកន្លែង ។

រឿងនេះ ក៏ដូចគ្នានឹងរឿងរបស់សិស្សនៃសាលារៀនពាក់កណ្ដាលពេលនៅទីក្រុងដែរ ។ ដោយធ្វើការជាមួយជាងទាំងឡាយ សិស្សអាចបណ្ដុះដល់ខ្លួនគេនូវគំនិតសួនរួម នូវទំលាប់គិតដល់សាធារណប្រយោជន៍ នូវន័យដ៏មានខ្លឹមសារនៃការចាត់ចែងនឹងវិន័យ ។ គេមាន ពុំមែនតែគំរិះនឹងពុទ្ធិតិកនិកប៉ុណ្ណោះទេ ប៉ុន្តែមានទាំងការពិសោធន៍ ក្នុងការអនុវត្តន៍និងមានសម្បទាច្បាស់លាស់ចំពោះការងារថែមទៀត ។

សព្វថ្ងៃនេះ ការពិសោធន៍លើសាលាដែលចងភ្ជាប់ការសិក្សា ជាមួយនឹងការងារឧស្សាហកម្មនឹងកសិកម្ម បានត្រូវបន្តដំណើរយ៉ាងគគ្រឹកគគ្រេងទូទាំងប្រទេស ។ ការចងភ្ជាប់ការសិក្សា ទៅនឹងការងារឧស្សាហកម្ម-កសិកម្មនេះ បញ្ជាក់នូវទិសដៅសំរាប់ការពង្រីកមានរយៈពេលវែង នៃការសិក្សាអប់រំសង្គមនិយមនៅប្រទេសចិន ។ ប្រព័ន្ធពេញលេញនៃ បឋម—មធ្យម—ឧត្តមសិក្សា នឹងត្រូវបង្កើតឡើង ដើម្បីទទួលកន្លែងដ៏សំខាន់មួយក្នុងការអប់រំ នៅប្រទេសចិន ។



# អក្សរសាស្ត្រ និង [illegible]

## កំណាព្យ

ខ្ញុំ សាង ជីវភាព

" ខ្ញុំសូមឧទ្ទិស   កំណាព្យនេះ   ជូនដល់មិត្តខ្ញុំទាំងអស់
ដែលធ្វើការនៅឯអនុវិទ្យាល័យព្រះសីហនុវង្ស នាស្រុកក្រូចឆ្មារ ,,

ទូកតូចកណ្ដាលទ្រូងមេគង្គ   រសាត់កំពុងកាត់ជលសា
ភូមិក្លែត ៗ តែឯកា   រសាត់ទៅណាខ្ញុំមិនដឹង ។

មេគង្គទឹកខ្លាំងកម្លាំងក្រៃ   ហូរទឹកចូលដៃបំពេញបឹង
ហូរនាំដីល្បប់លុបដីរឹង   សំឡឹងឃើញផលពេកសំរេក ។

ខ្សែទឹកហូរគួបរួមជាធ្លុង   ហូរពួយសំយុងហូរមិនមក
មិនត្រឡប់ក្រោយហូរនាំយក   ផលល្អឲ្យមកកម្ពុជា ។

ខ្សែទឹកហូររួមប្រៀបប្រដូច   ខ្មែរធំខ្មែរតូចរួមសាមគ្គា
ធ្វើការចំរើនដល់គាព   វប្បធម៌វិជ្ជានាជូនជាតិខ្មែរ ។

ទឹកហូរពុំឈប់ពុំចេះហត់   ខ្មែរមានអំណត់ដូចទឹកដែរ
មេគង្គឈប់ហូរទើបយើងកែ   ចិត្តផាកវេរែបរកខ្ជិលបាន ។

សំឡឹងទូកតូចខ្ញុំស្រណោះ    ទូកតូចហូរផ្ទោះខ្ញុំខាន
ដីវភាពកំពុងវណ្ដាំប្រាន    រុញប្រាណឲ្យឃ្លាតមិត្តភក្ដិ ។
ប្រឹងប្រែងអ្នកអុំខំកាយទឹក    ទឹកសាចហូរញឹកញើសថ្មីៗ
ហូរស្រោចពងកាយអ្នកឥតស្ដី    តើអុំរកអ្វីប្រាប់ខ្ញុំផង ?
ឬមួយអ្នកអុំរកកំពង់ ?    ឬមួយអ្នកលង់វង្វេងហោង ?
ឬមួយអ្នកអុំដើម្បីធ្វង    អុំកាត់រំលងភ័យអវិជ្ជា ។
សូមអុំត្រឡប់ចូលមកអាយ    អ្នកអុំស្រស់ស្រាយលើកដៃព
គ្រវីឡើងជាសញ្ញាលា    ថាលាខ្ញុំលាលាមិត្តសិន ។

ដោយ ម៉ម-ឆន្ទា

និ. សា. ថ្នាក់ខ្មែរឆ្នាំទី ១


**បណ្ណាគារអន្តរជាតិ** 150 G មហាវិថីនេរុ ភ្នំពេញ

សូមអញ្ជើញ មិត្តសមាជិកនៃសមាគមសាស្ត្រាចារ្យខ្មែរទៅទិញសៀវភៅ នៅបណ្ណាគារនេះ !

វង្វាន់២០ % នឹងមានធ្វើជូនបំពោះមិត្តណាដែលទៅទិញ ហើយបានបង្ហាញបណ្ណសមាជិក ។

មានលក់សៀវភៅសិក្សា សៀវភៅប្រលោមលោកជាភាសាខ្មែរ នឹងជាភាសាបារាំង; មានលក់ទស្សនាវដ្ដីដែលផ្សាយចេញនៅប្រទេសចិន វៀតណាម នឹងនៅសហភាពសូវៀត ហើយនឹងសៀវភៅសំរាប់បណ្ដុះវប្បធម៌ទូទៅជាច្រើនមុខទៀតជាភាសាបារាំង នឹង « អេស្ប៉េរ៉ង់តូ » ព្រមទាំង ......រូបតក្កាផង ។

# សេចក្ដីថ្វាយព្រះពរ



ក្នុងឱកាសពិធីចំរើនព្រះជន្មសម្ដេចឪ គំរប់ ៤៤ វស្សា សមាគមសាស្ត្រាចារ្យខ្មែរយើងបានផ្ញើថ្វាយចំពោះព្រះអង្គ នូវលិខិតថ្វាយព្រះពរមួយច្បាប់ កាលពីថ្ងៃទី ៣០ តុលា ១៩៦៥ ។

មកដល់ថ្ងៃទី ៣ វិច្ឆិកា ស. ស. រ. យើងបានទទួលនូវសេចក្ដីអំណរគុណមួយច្បាប់ពីសហជីវិន តាមលេខាធិការដ្ឋានផ្ទាល់នៃសម្ដេចព្រះប្រមុខរដ្ឋ ។

ខាងក្រោមនេះ គឺជាសេចក្ដីនៃលិខិតទាំងពីរ :

*នៅក្នុងឱកាសដ៏នក្ខត្តឫក្ស នៃពិធីចំរើនព្រះជន្មសម្ដេចឪគំរប់៤៤ ព្រះវស្សានេះ :*

*ទូលព្រះបង្គំទាំងឡាយ សមាជិកគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ ដែលជាកូនចៅសម្ដេចឪ សូមចូលរួមជាមួយនឹងប្រជាជាតិទាំងមូល សូមព្រះពជរពេកាសប្រសិទ្ធិថ្វាយសម្ដេចឪ នូវពរសព្ទសាធុការមហាប្រសើរដ៏លើសលុប សូមសម្ដេចឪ ទ្រង់ប្រកបទៅដោយព្រះជន្មាយុយឺនយូរ រាប់ជាងរយព្រះវស្សា ហើយសូមព្រះអង្គទ្រង់ប្រកបដោយមហាជោគជ័យសិរីមង្គលវិបុលសុខឈ្នះអស់មារសត្រូវគ្រប់ទិសទី*

*ដើម្បីទ្រង់គង់ជាម្លប់ ហើយនឹងជាព្រះអគ្គមគ្គុទ្ទេសក៍ នៃប្រជាជាតិខ្មែរទាំងមូល នៅលើមាគ៌ាដ៏រុងរឿងនៃសន្តិភាព ឯករាជ្យ អព្យាក្រឹត បង្រួបបង្រួមជាតិនិងវឌ្ឍនភាពដែលព្រះអង្គទ្រង់ជាព្រះស្ថាបនិករដំបូងដ៏អង់អាច ។*

*នៅក្នុងឱកាសដ៏ប្រសើរនេះ ទូលព្រះបង្គំទាំងឡាយ សូមថ្លែងថ្វាយសម្ដេចឪជាថ្មីទៀត នូវសេចក្ដីស្វាមីភក្ដិឥតរង្គោះរង្គើរបស់ទូលព្រះបង្គំ*

ខុទ្ទកាល័យនៃសម្ដេចសហជីវិន

ព្រះប្រមុខរដ្ឋ

**Cabinet de SAMDECH SAHACHIVIN**
**Chef de l'Etat**
**N° 1.448 S. P. U.**

# ព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ នៅថ្ងៃទី ៣ វិច្ឆិកា គ. ស. ១៩៦៥

នាយលេខាធិការដ្ឋានផ្ទាល់នៃសម្ដេចព្រះប្រមុខរដ្ឋ

សូមជំរាបមក គណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ

ក្រុងភ្នំពេញ ។

ខ្ញុំមានកិត្តិយសសូមថ្លែងជូនវិញ ក្នុងព្រះបរមនាមនៃសម្ដេចព្រះប្រមុខរដ្ឋ នូវអំណរគុណដ៏ជ្រាលជ្រៅចំពោះសហជីវិន ព្រមទាំងសហជីវិន- សហជីវិនីទាំងឡាយជាសមាជិក–សមាជិកានៃសមាគមនេះ ដែលបានរួបរួមគ្នាប្រសិទ្ធិស័ព្ទសាធុការពរថ្វាយព្រះអង្គ នៅក្នុងឱកាសព្រះរាជពិធីចំរើនព្រះវស្សា កាលពីថ្ងៃទី ៣១ តុលា ១៩៦៥ ។

សូមគុណបុណ្យព្រះរតនត្រ័យ នឹងព្រះបារមីនៃអតីតព្រះមហាក្សត្រគ្រប់ព្រះអង្គជួយថែបាច់រក្សាសហជីវិន – សហជីវិនីទាំងអស់ជាសមាជិក–សមាជិកា នៃសមាគមនេះ សុំឲ្យបានប្រកបតែនឹងសុភមង្គលវិបុលសុខគ្រប់ប្រការជានិច្ចកុំបីឃ្លៀងឃ្លាតឡើយ ។

សូមសហជីវិនទទួលនូវសេចក្ដីរាប់អានដ៏ជិតស្និទ្ធនឹងជាពិសេសអំពីខ្ញុំ ។

ហត្ថលេខា : ឆាន់ យូរ៉ាន់

---

តពីទំព័រទី ១១

ទាំងឡាយចំពោះព្រះរាជបល្ល័ង្ក ចំពោះសម្ដេចព្រះមហាក្សត្រិយានី ចំពោះព្រះអង្គសម្ដេចឪ នឹងចំពោះព្រះនយោបាយដ៏ភ្លឺស្វាងរបស់ព្រះអង្គ ហើយសូមប្ដេជ្ញាដង្ហែតាមព្រះអង្គនឹងព្រះរាជនយោបាយព្រះអង្គលុះដល់ទីអវសាន ។

សូមក្រាបបង្គំទូលថ្វាយ ភ្នំពេញនៅថ្ងៃ ៣០ តុលា ១៩៦៥



# មិត្តភាពរវាង ស.ស.ខ. និង សហជីពទូទៅ នៃ អ្នកអប់រំចិន

កាលពីថ្ងៃ ២៩ កញ្ញា ១៩៦៥ សមាគមយើងបានផ្ញើលិខិតមួយច្បាប់ ទៅសហជីពទូទៅ នៃអ្នកអប់រំប្រទេសចិន ដើម្បីនឹងប្រសិទ្ធិពរជល់ប្រទេសចិន ក្នុងឱកាសបុណ្យខួបទី ១៦ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន ។

នៅថ្ងៃ ៣ វិច្ឆិកា សហជីពអ្នកអប់រំចិនក៏បានឆ្លើយតបមកវិញ ។ ខាងក្រោមនេះ គឺជាអត្ថបទនៃលិខិតទាំង ២ :

សហសេវិកជាទីស្នេហា

នៅក្នុងឱកាសបុណ្យខួបទី ១៦ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន ដែលនឹងចូលមកដល់ក្នុងប៉ុន្មានថ្ងៃទៀតនេះ សមាគមសាស្ត្រាចារ្យខ្មែរមានសេចក្ដីរីករាយយ៉ាងក្រៃលែង នឹងសូមសំដែងហើយប្រសិទ្ធជូនសមាជិកគណៈកម្មាធិការកណ្ដាល ព្រមទាំងសមាជិកនៃសហជីពអ្នកអប់រំចិនទាំងមូលនូវសេចក្ដីសរសើរយ៉ាងខ្លាំងក្លា ហើយនឹងពរសព្វសាធុការមហាប្រសើរដើម្បីសេចក្ដីសុខនឹងសេចក្ដីចំរើនសព្វបែបយ៉ាង ។

ព្រមជាមួយនេះ យើងខ្ញុំសូមសំដែងនូវសេចក្ដីកោតស្ញប់ស្ញែងយ៉ាងជ្រាលជ្រៅរបស់យើង ដល់មហាប្រជាជនចិនជាមិត្ត ចំពោះជោគជ័យដ៏សំបើមអស្ចារ្យដែលប្រជាជននេះបានសំរេចនៅក្នុងគ្រប់វិស័យ សេដ្ឋកិច្ច នយោបាយ វប្បធម៌ សង្គមកិច្ច ការការពារប្រទេស ជំនួយដល់ប្រទេសជាមិត្ត ការគាំទ្រចលនារំដោះជាតិ នឹងការការពារសន្តិភាពសាកលលោក ។ យើងខ្ញុំជឿជាក់ថា ក្នុងមហា

បាតុកម្មនៅមុខទ្វារទានអានមីនឆ្នាំនេះ ប្រជាជនជាកៀវដែលបានអញ្ជើញពីទ្វីបទាំងប្រាំទៅ ប្រាកដជានឹងភ្ញាក់ ចំពោះសមិទ្ធិដ៏សំបើមថ្មី ៗ ទៀតជាមិនខាន ។ ក្នុងឆ្នាំនេះ យើងខ្ញុំមានកិត្តិយសជាពិសេស ដោយប្រទេសកម្ពុជាយើងមានគណៈប្រតិភូមួយដ៏សំខាន់ ដែលមានអង្គសម្តេចព្រះប្រមុខរដ្ឋទ្រង់ជាអ្នកដឹកនាំ មានគណៈប្រតិភូនៃសមាគមមិត្តភាពខ្មែរ-ចិន ហើយនឹងគណៈប្រតិភូកីឡាយើង ដែលនឹងបានចូលរួមក្នុងសេចក្តីសប្បាយរីករាយ ហើយនឹងមោទនភាពដ៏សមហេតុផលនៃប្រជាជនចិន ហើយមានឱកាសនឹងធ្វើគារវកិច្ចដ៏ស្មោះស្ម័គ្រចំពោះប្រជាជនចិនដ៏ជោគជ័យនឹងចំពោះអ្នកដឹកនាំដ៏ក្លៀវក្លានៃប្រជាជននេះ ជាអាទិចំពោះលោកប្រធាន ម៉ៅ សេ ទុង ។

សូមឱ្យចំណងមេត្រីភាពរវាងសមាគមសាស្ត្រាចារ្យខ្មែរ នឹងសហជីពអ្នកអប់រំចិនរីកចំរើនឡើង ហើយឋិតថេរថេរកាលអង្វែងតទៅ !

សូមឱ្យប្រជាជនចិនយកបានជ័យជំនះកាន់តែច្រើន ហើយកាន់តែធំឡើងទៀតក្នុងគ្រប់រណសិរ្ស !

ភ្នំពេញ ថ្ងៃទី ២៩ កញ្ញា ១៩៦៥

Comité national du Syndicat des
Enseignants de Chine

Pékin, le 3 novembre 1965

A l'Association des Professeurs Khmers
123 E MV Préah Sihanouk
Phnom-Penh
CAMBODGE

Chers collègues,

Nous avons été très heureux de recevoir, par l'intermédiaire de notre ambassade au Cambodge, la lettre de félicitations qui nous a été adressée par le président de votre Association à l'occasion du 16 ème anniversaire de la fondation de notre République Populaire. Pour cela, nous vous prions de recevoir nos sincères remerciements.

Cette année, plus de 2.000 invités venus de plus de 80 pays et territoires du monde ont participé aux côtés de notre peuple à la célébration de notre fête nationale. Nous avons été particulièrement honorés pa la présence de votre chef d'Etat, S.A. le prince Norodom Sihanouk qui a conduit personnellement une délégation pour venir participer aux célébrations de notre fête. Les visites qu'il a effectuées en différents endroits de notre pays et des discours qu'il y a prononcés constituent un grand encouragement pour nos travailleurs et notre peuple qui poursuivent activement la révolution et l'édification socialistes. Il a reçu partout un chaleureux accueil de la part de toutes les couches populaires La visite des invités Khmers ainsi que la déclaration commune des deux pays ont apporté une nouvelle contribution au renforcement de l'amitié traditionnelle et de la coopération entre les deux peuples.

Le peuple chinois se réjouit cordialement de toutes les réalisations que votre peuple a accomplies dans les domaines de l'industrie, de l'agriculture, de la culture et de l'éducation ainsi que la santé publique. Nous vouons une grande admiration au peuple Khmer qui, après avoir rejeté «l'aide américaine», s'est engagé encore plus résolument dans la voie d'un développement indépendant. Beaucoup d'enseignants ont visité ici à Pékin l'exposition « le Cambodge d'aujourd'hui » consacrée aux réalisations de l'édification de votre pays. Nous avons été tous très touchés par la volonté de votre peuple de déployer tous vos efforts pour construire le pays.

Actuellement, l'impérialisme américain, le pire ennemi de tous les peuples, poursuit partout une politique d'agression et de guerre, ce qui oblige les peuples à mener une lutte à mort contre lui. Il s'emploie activement à étendre la guerre d'agression au Sud-Vietnam et cherche à allumer le feu de la guerre sur toute l'Indochine et tout le Sud-Est asiatique. Il ne cesse de faire des provocations et de proférer des menaces contre le Royaume du Cambodge. Actuellement, votre peuple et tous les peuples d'Indochine se tiennent aux premiers rangs de la lutte contre l'impérialisme américain. Vous luttez non seulement pour défendre votre patrie mais aussi pour apporter une contribution à la sauvegarde de l'indépendance et de la sécurité de tous les peuples du Sud-Est asiatique. Les travailleurs et le peuple de notre pays soutiennent votre lutte comme ils soutiennent celle des frères et soeurs vietnamiens, et mèneront jusqu'au bout la lutte contre notre ennemi commun, l'impérialisme américain.

Puisse l'amitié entre les enseignants et les peuples de nos deux pays durer éternellement comme les eaux du Mékong qui lie nos deux pays.

*Comité national du Syndicat des*
*Enseignants de Chine*

## ស.ស.ខ. ទទួលអំណោយសៀវភៅ អំពីវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ



កាលពីថ្ងៃ ២៨ តុលា ១៩៦៥ នៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ មានធ្វើពិធីប្រគល់ចំពោះ ស.ស.ខ. នូវសៀវភៅចំនួនជាច្រើនមួយរយក្បាល ដែលវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ បានផ្តល់ជាអំណោយចំពោះសមាគមយើង តាមសេចក្តីសុំរបស់យើង ។

មុនចាប់ផ្តើមពិធី មិត្តលាង ហាប់អាន - នាយកវិជ្ជាស្ថានបានធ្វើការណែនាំឲយស្គាល់នូវនាមនិងមុខងាររបស់មន្ត្រីនានា ដែលបានចូលមករួមជាប្រធានក្នុងពិធីនេះ ។ បន្ទាប់មក នាមនិងមុខងាររបស់សមាជិកគណៈកម្មាធិការនាយកនៃ ស.ស.ខ ដែលបានចូលទៅរួមក្នុងពិធីនេះគ្រប់គ្នាទាំងអស់ ក៏ត្រូវបានបង្ហាញតបទៅវិញដោយមិត្តប្រធាន មាស ខឹម ។

ពិធីចាប់ផ្តើម: មិត្តនាយកវិជ្ជាស្ថាន បានថ្លែងសុន្ទរកថាមួយរៀបរាប់ពី វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ និងដើម្បីប្រគល់សៀវភៅ ។ តមកទៀត មិត្តប្រធានសមាគមយើងក៏បានធ្វើសុន្ទរកថា សំដែងសេចក្តីរីករាយនិងអំណរគុណ ចំពោះអំណោយដ៏សប្បុរស និងដ៏ថ្លៃថ្លានេះ ។

ខាងក្រោមនេះ យើងសូមចុះជូនមិត្ត នូវសេចក្តីនៃសុន្ទរកថាទាំង ២ :

សហជីវិនប្រធាន

សហជីវិនី - សហជីវិន

ថ្ងៃនេះជាទិវាដ៏ប្រសើរ ដែលយើងទាំងអស់គ្នា បានជួបជុំក្នុងមជ្ឈមណ្ឌលប្រកបដោយគ្រឿងខ្នាតជាឫសគល់របស់វប្បធម៌ អក្សរសាស្ត្រជាតិ ។ គឺជាលើកដំបូងបំផុតហើយ ដែលវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ បានរៀបចំពិធីតូចមួយបែបនេះ ដើម្បីជានិមិត្តរូបនៃការទាក់ទងផ្សាយនូវឯកសារជាស្នាដៃកើតឡើងដោយវិរិយភាព យ៉ាងប្ដូរផ្ដាច់របស់អ្នកប្រាជ្ញគន្ថបណ្ឌិតសម័យបុរាណនិងសម័យថ្មីរបស់ជាតិ ។ គោលបំណងធំរបស់វិជ្ជាស្ថានយើងពុំមែនមានត្រឹមតែការប្រមូលរក្សាទុកឯកសារជាតិ បរទេស ដែលទាក់ទងខាងពុទ្ធសាសនាប៉ុណ្ណោះទេ គឺបានទាំងទទួលយកមកដំកល់ទុកក្នុងបណ្ណាល័យរបស់ខ្លួន នូវស្នាដៃខាងប្រវត្តិវិជ្ជា ទស្សនវិជ្ជា មនុស្សវិជ្ជា ព្រមទាំងឯកសារគ្រប់បែបយ៉ាង ដែលទាក់ទងខាងបុរាណវិជ្ជា មានចំណេះចេះដឹងខាងអារ្យធម៌ ទំនៀមទម្លាប់ប្រពៃណីជាដើមថែមទៀតផង ។ គេច្រើនយល់ច្រឡំថា វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យនេះ គឺជាកន្លែងបង្រៀនធម៌អាថ៌ខាងពុទ្ធសាសនាចំពោះព្រះភិក្ខុសង្ឃ ដូចជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ឬពុទ្ធិកមហាវិទ្យា-ល័យព្រះសីហនុរាជយ៉ាងនោះដែរ ។ ការពិតគឺមជ្ឈមណ្ឌលទាំងបីនេះ គ្រាន់តែឋិតនៅក្រោមឱវាទក្រសួងធម្មការដូចគ្នា ប៉ុន្តែមានមុខការ និងមានដំណើរការប្រព្រឹត្តទៅខុសគ្នា ហើយឋិតនៅក្រោមការត្រួតត្រារបស់អ្នកគ្រប់គ្រងផ្សេងគ្នាទៀត ។ ពុទ្ធិកសិក្សាទាំងពីរផ្នែក គឺពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត និងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជមានភារៈអប់រំបង្រៀន វិជ្ជាផ្លូវលោក និងផ្លូវសាសនាចំពោះព្រះភិក្ខុសង្ឃមែន ។ ប៉ុន្តែចំណែកខាងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យឯណោះ មិនដូច្នោះទេ គឺជាក្រសួងវប្បធម៌មួយរបស់ជាតិគ្រប់គ្រងដោយនាយក ដែលមានអគ្គលេខាធិការ និងអគ្គលេខាធិការរងជាជំនួស ។ វិជ្ជាស្ថាននេះចែកជា ៦ ការិយាល័យ ដែលមាននាយការិយាល័យព្រមទាំងបុគ្គលិកធ្វើការទទួលខុសត្រូវរៀង ៗ ខ្លួន ។ ការិយាល័យទាំង ៦ នោះមាន :

១– ការិយាល័យក្រុមជំនុំព្រះត្រៃបិដក ដែលមានសម្ដេចព្រះពោធិវង្ស ជាព្រះអធិបតី និងព្រះតេជៈព្រះគុណ ព្រះមុនីកោសល ស្វ-ហាយ ជាអធិបតីរង ។ ការិយាល័យនេះបានពិនិត្យប្រែផ្ទៀងផ្ទាត់ នូវគម្ពីរព្រះត្រៃបិដករួចបស់សព្វគ្រប់ ចំនួន ១១០ ក្បាលហើយ សព្វថ្ងៃនេះ បានបោះពុម្ពផ្សាយដោយប្រាក់ថវិកាជាតិ បានចំនួន ៨៣ ក្បាលហើយ ។

២– ការិយាល័យទំនៀមទម្លាប់ ដែលទទួលរ៉ាប់រងប្រមូលចងក្រងសំរាំងឯកសារទាក់ទងខាងទំនៀមទម្លាប់ជាតិ ហើយក្នុងមួយឆ្នាំ ៗ បានប្រកាសបើកការប្រឡង ២ លើក គឺ១ឆមាសម្ដង ។ សព្វថ្ងៃ ការិយាល័យនេះ មានឯកសារចំនួនជាង៣០០០ រឿង ។ យើងមានអ្នកឆ្លើយឆ្លងផ្ដល់ពត៌មាននៅគ្រប់ជនបទ និងខេត្តនានានៃព្រះរាជអាណាចក្រ ។

៣– ការិយាល័យបណ្ណាល័យ ដែលមានចំនួនសៀវភៅ និងឯកសារគ្រប់ភាសាដល់ទៅ ៣៩.៥៣២ ក្បាល ។ សៀវភៅទាំងអស់នេះ ចែកជាបីផ្នែក គឺ :

– ផ្នែកភាសាអឺរុប
– ផ្នែកភាសាបូពាំទិស
– និងផ្នែកក្រាំងព្រមទាំងសាស្ត្រាស្លឹករឹត

បណ្ណាល័យនេះមានទំហំតូច ព្រមទាំងមានចំនួនសៀវភៅតិចទេ ប៉ុន្តែគុណភាពខាងឯកសារសំខាន់ណាស់ ព្រោះជាឃ្លាំងក្បួនខ្នាតដ៏ចាំបាច់កម្ររកបានក្នុងទីដទៃ ហើយដែលអ្នកប្រាជ្ញ អ្នកស្រាវជ្រាវពុំអាចចៀសវាងកន្លងទីនេះបានឡើយ ។

៤– ការិយាល័យរបៀបនិងបុគ្គលិក

៥– ការិយាល័យគណនេយ្យ ទទួលភារៈគ្រប់គ្រងឃ្លាំងសៀវភៅ មើលការខុសត្រូវខាងកិច្ចការ ប្រាក់ចំណូល ចំណាយ និងការលក់សៀវភៅបោះពុម្ពផ្សាយដោយវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យនេះ ។

៦– ការិយាល័យបោះពុម្ពផ្សាយសៀវភៅនានា ព្រមទាំងទស្សនាវដ្ដីកម្ពុជសុរិយា ។ ចំពោះសៀវភៅជាភាសាជាតិ ទាំងខាងផ្លូវលោក ទឹងផ្លូវធម៌ ព្រមទាំងសៀវភៅសិក្សាដែលវិជ្ជាស្ថានបានបោះពុម្ពផ្សាយជាចែកជូនសព្វថ្ងៃនេះ មានចំនួនជាង ២០០មុខ ។ ចំណែកឯទស្សនាវដ្ដី កម្ពុជសុរិយា ដែលមានកំណើតនៃការផ្សាយ តាំងពីឆ្នាំ១៩២៧មក សព្វថ្ងៃ គឺជាទស្សនាវដ្ដីជាតិតែមួយ ដែលមានអាយុកាលចាស់ជាងគេហើយមានខ្លឹមសារយ៉ាងពិសេស ខាងវិជ្ជាផ្លូវសាសនា និងផ្លូវលោក ។

## សហជីវិនី - សហជីវិន

សមិទ្ធិដែលបិតនៅចំពោះមុខ ហើយដែលបានផ្ដល់ជូនជាអំណោយចំពោះសមាគមសាស្ត្រាចារ្យនេះ ហើយដែលជាលទ្ធផលនៃស្នាដៃស្រាវជ្រាវចងក្រង និពន្ធឡើងរបស់បុគ្គលិក ជាព្រះសង្ឃនិងគ្រហស្ថ ដែលជាអ្នកប្រាជ្ញ គន្ថបណ្ឌិតដ៏ឆ្នើមក្នុងអតីតកាលព្រមទាំងបច្ចុប្បន្នកាល ធ្វើការក្នុងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ និងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដែលពីដើមហៅថាសាលាបាលីជាន់ខ្ពស់ នៃក្រសួងធម្មការនេះ ជាពិសេសគឺមានសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ជោតញាណោ ជួន ណាត និងសម្ដេចព្រះពោធិវង្ស ហួត តាត អគ្គាធិការនៃពុទ្ធិកសិក្សាជាដើម ។ ដោយអំណោយស្ដួចស្ដើង ប៉ុន្ដែមានខ្លឹមសារ និងទឹកដមខាងវប្បធម៌ អក្សរសាស្ត្រជាឫសគល់របស់ជាតិនេះ វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ សូមសមាគមសាស្ត្រាចារ្យ ដែលមានសមាជិកជាងមួយពាន់បីរយរូប មេត្តាយកទៅផ្សាយចំពោះសិស្សានុសិស្ស ឲ្យបានជ្រួតជ្រាបផង ។

ជាទីអវសាន វិជ្ជាស្ថានសូមជូនពរសព្វសាធុការចំពោះសមាគមសាស្ត្រាចារ្យ ព្រមទាំងសមាជិករបស់អង្គការនេះទាំងអស់ សូមបានប្រកបដោយវឌ្ឍនភាពចំរុងចំរើនកើនឡើងជាលំដាប់ កុំបីឃ្លៀងឃ្លាតឡើយ ។

សហជីវិន - សហជីវិនី

មិត្តទាំងឡាយ

យើងខ្ញុំមានសេចក្ដីរំភើបជាពន់ពេក ដោយបានមកកាន់វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលជាមជ្ឈដ្ឋានប្រកបដោយក្បួនខ្នាតជាឫសគល់វប្បធម៌ អក្សរធម៌ខ្មែរ ហើយដែលយើងទាំងអស់គ្នាចេះតែប្រឡំនឹងសាលាបាលីជាន់ខ្ពស់ ដែលសព្វថ្ងៃនេះគឺជាពុទ្ធិកសិក្សាថ្នាក់មធ្យមនិងឧត្ដមសិក្សា ប្រឡំនឹងក្រសួងធម្មការថែមទៀតផង ។ យើងខ្ញុំសូមថ្លែងអំណរគុណដ៏លើសលប់ចំពោះពត៌មានដ៏ប្រសើរនេះ ព្រមទាំងចំពោះពរសព្ទសាធុការដល់សមា-គមយើងឲ្យមានវឌ្ឍនភាព ចំរុងចំរើនទៅមុខដែលសហជីវិនបានប្រសិទ្ធិដល់យើង នឹងដល់សមាគមយើងដោយមេត្រីភាពអម្បាញមិញនេះ ។

ពិតណាស់ហើយ វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យនេះ ជាមជ្ឈមណ្ឌលចាស់បុរាណមួយដែលថែរក្សាទុកនូវឯកសារគ្រប់បែបយ៉ាងនៃវប្បធម៌ អក្សរធម៌ជាតិយើង ជាមជ្ឈដ្ឋាននៃបណ្ឌិត បុរោហិត គន្ថបណ្ឌិត អ្នកប្រាជ្ញគ្រប់ផ្នែក ទោះជាខាងសាសនាក៏ដូចជាខាងវប្បធម៌ឯទៀត បានសិក្សារុករក និងបង្កើតនូវគម្ពីរដីកាក្បួនខ្នាតគ្រប់បែបយ៉ាង ព្រមទាំងវិលទៅប្រមូលកេរ្ដិ៍ដំណែលដ៏មានតម្លៃ ពីដូនតារបស់ជាតិយើង ហើយដែលពត់ពយពាសពេញទាំងព្រះរាជអាណាចក្រ ។ មានឯកសារខ្លះសឹងតែបាត់បង់ទៅហើយ ហើយការរុករកនៃអ្នកប្រាជ្ញទាំងនោះ បានធ្វើឲ្យមានជីវិតឡើងវិញនូវគម្ពីរដីកាដែលស្មានថានឹងអស់ជីវិតទៅហើយ ។

កិច្ចការដែលមានតម្លៃរកកាត់ថ្លៃពុំកើត ដែលខេមរបណ្ឌិត្យទាំងព្រះសង្ឃនិងគ្រហស្ថបានអនុវត្តឡើង គឺកិច្ចការនៃក្រុមជំនុំព្រះត្រៃបិដក ដែលជាកេរ្ដិ៍ដំណែលក្នុងព្រះពុទ្ធ-សាសនា ហើយដែលប្រជាជាតិខ្មែរយើងទទួលស្គាល់និងទុកជាសក្ការបូជាទូទាំងប្រទេស ។ ការកសាងព្រះត្រៃបិដកនេះជាភ័ស្ដុតាងមួយយ៉ាងប្រត្យក្សបំផុតនៃវិរិយភាព កំរិតចំណេះចេះដឹងយ៉ាងខ្ពង់ខ្ពស់នៃអ្នកប្រាជ្ញបណ្ឌិត្យជនជាតិយើង ។ ក្នុងបណ្ដាអ្នកប្រាជ្ញទាំងនេះ

សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ជោតញ្ញាណោ ជួន-ណាត ទ្រង់ជាព្រះអង្គប្រមុខគ្មានអ្នកណាអាចប្រៀបនឹងព្រះបញ្ញាញាណរបស់ព្រះអង្គ ក្នុងវិស័យអក្សរសាស្ត្រ វប្បធម៌ អារ្យធម៌ជាតិយើងនេះបានឡើយ ។ ព្រះអង្គពុំគ្រាន់តែជាអ្នកប្រាជ្ញក្នុងកម្ពុជរដ្ឋប៉ុណ្ណោះទេ គឺជាអ្នកប្រាជ្ញដែលប្រទេសឯទៀតជាច្រើនបានទទួលស្គាល់ នឹងលើកព្រះឋានៈជា „ មហា. បណ្ឌិត „ ទៀតផង ។

ឯកសារសំខាន់មួយទៀត ក្នុងការសិក្សាអក្សរសាស្ត្រខ្មែរ ហើយដែលខ្មែរភាគច្រើនពុំទាន់ទទួលស្គាល់នូវតម្លៃនៅឡើយ គឺរឿងរាមកេរ្តិ៍នេះឯង ។ រឿងរាមកេរ្តិ៍អាចយកទៅសិក្សាបានគ្រប់ថ្នាក់ ចាប់តាំងពីមធ្យមសិក្សារហូតដល់ឧត្តមសិក្សា ។ កាលបើបានសិក្សាយូរទៅ គេកាន់តែឃើញច្បាស់នូវតម្លៃ ហើយអត្ថនេះ រសជាតិនេះលេចចេញពីគ្រប់ទំព័រទាំងឡាយនៃគម្ពីរនេះ ចេះតែមានជានិច្ចពុំចេះហួតហែងរីងស្ងួតសោះឡើយ ។ រឿងរាមកេរ្តិ៍ ពុំគ្រាន់តែជាអត្ថបទអក្សរសិល្ប៍ប៉ុណ្ណោះទេ គឺជាអត្ថបទសម្រាប់សិក្សាគ្រប់វិជ្ជាក្នុងអក្សរសាស្ត្រ ជាក្បួនវេយ្យាករណ៍ ជាក្បួនប្រើពាក្យដែលបុរាណាចារ្យខ្មែរយើងមានបំណងទុកជាឋាមភាពតាំងពីសម័យអង្គរមកម្ល៉េះនោះថែមទៀតផង ។ ក្នុងមធ្យមសិក្សានឹងឧត្តមសិក្សា សាស្ត្រាចារ្យបានចាត់ទុក ឯកសារនេះជាតម្លៃមួយពុំអាចកាត់បាន ។

ខ្ញុំជឿជាក់ថា នៅមានឯកសារច្រើនទៀត ដែលមានតម្លៃលើសលប់កាត់ពុំបានយ៉ាងនេះច្រើន ច្រើនឥតគណនា តែដោយខ្វះពេលវេលា នឹងបញ្ញាញាណរបស់ខ្ញុំពុំហុចឲ្យរៀបរាប់បានសព្វគ្រប់ ។

ការរៀបរាប់មកនេះ ក៏គ្មានបំណងអ្វីនឹងរំលឹកនូវសារប្រយោជន៍ នឹងតម្លៃវិជ្ជាស្ថានដែលខ្មែរភាគច្រើនពុំបានគិតដល់ ឬសឹងតែភ្លេចខ្លះទៅហើយ ដោយមានវិជ្ជាស្ថានឯទៀតកើតក្រោយ មានអគារធំៗ ថ្មីៗ តាមជាន់សម័យ ភ្លេចឯខ្លឹមសារហិតប្រយោជន៍នៃមជ្ឈដ្ឋានវប្បធម៌ អារ្យធម៌ខ្មែរមួយនេះ ។ ការរៀបរាប់មកប៉ុណ្ណោះក៏ហាក់ដូចជាអំពាវនាវ

ដល់យុវជន ដល់សាស្ត្រាចារ្យ ដល់អ្នកស្នេហាអក្សរសាស្ត្រជាតិ វប្បធម៌ អារ្យធម៌ជាតិ ឲ្យចូលមកសិក្សារុករកនិងបង្កើនតទៅទៀតនូវកេរ្ដិ៍ដំណែលដ៏មានតម្លៃបែបនេះ ។

សមាគមសាស្ត្រាចារ្យខ្មែរ ប្ដេជ្ញាថានឹងរួបរួមចូលមកសិក្សា ចូលមករុករកដើម្បីបន្ថែមការចេះដឹងរបស់ខ្លួនក្នុងវិស័យវប្បធម៌ អារ្យធម៌ អក្សរសាស្ត្រជាតិ និងលើកតម្លៃមជ្ឈមណ្ឌលនេះផង ។ ការប្រគល់សៀវភៅដ៏មានតម្លៃរកកាត់ពុំបាន ដោយសប្បុរសអំពីសហជីវិននាយកវិជ្ជាស្ថាន ជាជំហានដំបូងដែលដឹកនាំឲ្យពួកសាស្ត្រាចារ្យយើង ឲ្យមកស្គាល់កាំជណ្ដើរទី ១ នៃវិជ្ជាស្ថាន ហើយនឹងបន្តបំណងសិក្សានេះទៅអនាគតមិនឲ្យដាច់សោះឡើយ ។ ម្យ៉ាងទៀតគម្ពីរដីកា និងក្បួនខ្នាតទាំងនេះ ដែលសមាគមយើងបានទទួលដោយអំណរគុណនឹងកតញ្ញូតាធម៌ យើងខំនឹងរក្សាទុកមិនឲ្យខូចខាតបាត់បង់ ព្រមទាំងនាំគ្នាយកទៅសិក្សារៀនសូត្របង្កើនកំរិតនៃការចេះដឹងតទៅទៀត ជាប្រយោជន៍សាធារណផង ព្រមទាំងផ្សាយវប្បធម៌នេះទៅគ្រប់មជ្ឈដ្ឋានតាមសំណូមពររបស់សហជីវិននាយកវិជ្ជាស្ថាន ។

ក្នុងទីអវសាន សមាគមសាស្ត្រាចារ្យសូមប្រសិទ្ធិឲ្យគោលបំណងនេះរស់រវើកជានិច្ច ដើម្បីសម្រេចដល់ទីដៅនៅចុងក្រោយបំផុត សូមបំណងការសិក្សានេះរឹតតែមានទឹកដមជានិច្ច ក្នុងចិត្តគំនិតអ្នកស្នេហាអក្សរសាស្ត្រ វប្បធម៌ និងអារ្យធម៌ខ្មែរ ។ សូមគុណបុណ្យព្រះរតនត្រ័យនិងវត្ថុស័ក្ដិសិទ្ធិក្នុងលោកជួយប្រសិទ្ធពរ ឲ្យមជ្ឈមណ្ឌលពុទ្ធសាសនបណ្ឌិត្យនេះមានវឌ្ឍនភាពចំរុងចំរើនជានិច្ចកាល សូមគន្ថបណ្ឌិតបុរោហិតទាំងអស់បានប្រកបតែនឹង អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈជានិច្ចនិរន្តរ៍ ដើម្បីជាម្ចប់នៃការចំរើនលូតលាស់នៃវប្បធម៌ និងអារ្យធម៌ជាតិខ្មែរយើងកុំបីឃ្លៀងឃ្លាតឡើយ ។

ដោយ — វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

# ដំណឹងពីមិត្តយើង

● យើងមានសេចក្ដីក្រៀមក្រំជាពន់ពេក ដោយបានដំណឹងថា លោក វង់ ឃិន អធិការបច្ចេកទេសបានត្រូវចោរលួច កន្ទុកាសរៀបចំផ្ទះនៅភ្នំពេញ ដែលលោកត្រូវផ្លាស់មកកាន់ដំណែងថ្មី ។ ការបង់ខាតមានប្រហែលជា ១ ម៉ឺនរៀល ។

● យើងបានទទួលដំណឹងដោយរីករាយអំពី ពិធីរៀបអាពាហ៍ពិពាហ៍នៃ :

- មិត្ត ខៀវ គូឡា ជាមួយ កញ្ញា លៀង លាងហួ
- មិត្ត អ៊ុន ហួ ជាមួយ កញ្ញា ហ៊ុ ណារិន
- មិត្ត សេក ទ្រី ជាមួយ កញ្ញា ភិន គិមលី
- មិត្ត សៀវ ប៊ូស៊ុន ជាមួយ កញ្ញា ហាវ គឹមហេង ។

សូមជោគជ័យនឹងសេចក្ដីសុខគ្រប់ប្រការ កើតមានដល់គូស្រករថ្មីទាំងប្អូន កុំបីឃ្លៀងឃ្លាតឡើយ ។

● ជាចុងក្រោយបង្អស់ យើងបានទទួលពីអនុវិទ្យាល័យត្បូង (ក្រចេះ) នូវដំណឹងអំពីសេចក្ដីក្រៀមក្រំដែលបានធ្លាក់ទៅលើមិត្ត ម៉ុ - ឈាវ ដោយហេតុមាតារបស់មិត្តទើបនឹងទទួលអនិច្ចកម្មទៅ កាលពីថ្ងៃ ១៩ វិច្ឆិកា ១៩៦៥ នេះ នៅខេត្ត តាកែវ ដោយរោគាពាធ ។ សមាជិកទាំងអស់នៃអនុវិទ្យាល័យត្បូងរបស់យើងបានចូលរួមមរណទុក្ខនេះគ្រប់ៗគ្នា ។

សូមមិត្ត ម៉ុ - ឈាវ ទទួលនូវសេចក្ដីក្រៀមក្រំចិត្តនៃមិត្តសមាជិកគណៈកម្មាធិការនាយកទាំងអស់ដែលសូមចូលរួមរំលែកមរណទុក្ខនេះគ្រប់ៗគ្នាផង ។




● កាលពីថ្ងៃទី ៩ ខែតុលា ១៩៦៤ មិត្ត ប៉ូច សេង ចាងហ្វាងអនុវិទ្យាល័យព្រៃដើមថ្នឹង បានរៀបពិធីជុបលៀងមួយជូនចំពោះលោកចៅហ្វាយស្រុកថ្មី ។ ពិធីនេះប្រព្រឹត្តទៅក្នុងបរិយាកាសមិត្តភាពស្និទ្ធស្នាលជាទីពេញចិត្ត ដោយមានមិត្តចាងហ្វាងអនុវិទ្យាល័យព្រែកសណ្តែកនឹងសហការីខ្លះចូលរួមជាមួយផង ។

● កាលពីថ្ងៃទី ៦ វិច្ឆិកា ១៩៦៤ មានការប្រកួតកីឡាជាមិត្តភាពរវាងអនុវិទ្យាល័យព្រៃដើមថ្នឹង និងសាលាបឋមសិក្សាព្រៃដើមថ្នឹងខាងត្បូង ។

នៅថ្ងៃទី ១៣ ខែដដែល អនុវិទ្យាល័យយើងខាងលើនេះ បានប្រកួតកីឡាជាមិត្តភាពនឹងសាលាបឋមសិក្សា អំបែងបែះម្តងទៀត ។

លោកចៅហ្វាយស្រុក ព្រមទាំងសហការីខ្លះក៏បានចូលទៅរួមក្នុងការប្រកួតទាំងពីរលើកនេះដែរ ។

● នៅដំណាច់ខែតុលាមុននេះ មិត្ត ស៊ឹម ហុង នាយកវិទ្យាល័យពស្ត្រនិយមព្រះសីហនុ (តាខ្មៅ) បានធ្វើការប្រជុំសាស្ត្រាចារ្យនឹងបុគ្គលិកការិយាល័យទាំងអស់ ដើម្បីពិនិត្យរួមគ្នានូវលទ្ធផលនៃការសិក្សារបស់សិស្ស ក្នុងរយៈវេលាចាប់ពីបវេសនកាលមកទល់នឹងដំណាច់ខែតុលា ។

ពេលពោលដល់ ស. ស. ខ. មិត្តនាយកវិទ្យាល័យបានអំពាវនាវសាស្ត្រាចារ្យខ្មែរទាំងអស់ ជាពិសេសសាស្ត្រាចារ្យខ្លះដែលទើបនឹងចេញពីមហាវិទ្យាល័យគរុកោសល្យ ហើយដែលពុំទាន់ចូល ឲ្យចូលជាសមាជិក ស. ស. ខ. យើងទាំងអស់គ្នា ។

• កាលពីថ្ងៃទី ៩ ធ្នូ សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាល័យព្រះមហាក្សត្រិយានីកុសុមៈ (ក្រចេះ) បានទៅប្រកួតកីឡាជាមិត្តភាព ជាមួយនិងក្រុមកីឡាបុគ្គលិកនិងសាស្ត្រាចារ្យនៃអនុវិទ្យាល័យ "ព្រះរាជបូជនីយកិច្ច" ខេត្តស្ទឹងត្រែង ។

នៅយប់នោះ ក្រុមកីឡាវាយកូនឃ្លីលើតុក៏បានចាប់ប្រកួត ។ ការប្រកួតនេះត្រូវបានបញ្ចប់ដោយរាត្រីរាំវង់យ៉ាងរីករាយដែលរៀបចំដោយមិត្តសាស្ត្រាចារ្យ និងសិស្សនៃអនុវិទ្យាល័យខាងលើ ដើម្បីសំដែងមិត្តភាព ភាតរភាពរវាងបងប្អូនផង ដើម្បីជាកិច្ចស្វាគមន៍ទិវាសិទ្ធិមនុស្សផង ។

ស្អែកឡើងថ្ងៃទី ១០ ធ្នូ ថ្ងៃបុណ្យសិទ្ធិមនុស្ស មិត្តយើងក៏បានចាប់ប្រកួតកីឡាបាល់ទះ ។ ពេលរសៀលគឺជាពេលប្រកួតកីឡាបាល់ទាត់ ។ ក្នុងការប្រកួតទាំង ២ លើកខាងក្រោយនេះ លោកប្រមុខខេត្តនិងភ្នាក់ងាររាជការក៏បានមកទស្សនាកំសាន្តផង ។ ឯមហាជនមួយចំនួនធំ ក៏បានឆ្លៀតឱកាសមកទស្សនាយ៉ាងរីករាយដែរ ។ នៅពេលឈប់សំរាកម្តងៗ ក៏ដូចជានៅពេលចប់ការប្រកួត គេទាំងឡាយក៏បានទះដៃលាន់ឮរំពងយ៉ាងវែង ដើម្បីជាការសំដែងនូវបីតិរីករាយនិងជាសញ្ញាប្រសិទ្ធិពរជោគជ័យ ក្នុងឱកាសទិវានៃសិទ្ធិមនុស្សដល់បងប្អូន ។ កីឡាករក៏ដូចជាទស្សនិកជន ពេលបែកគ្នា គេបែកដោយទឹកមុខញញឹមព្រមទាំងដក់ជាប់ក្នុងចិត្តនូវសេចក្តីសង្ឃឹម និងការពេញចិត្តរបស់គេ បំពោះខ្លឹមសារដ៏សំខាន់នៃការប្រកួតនេះ ដែលមួយផ្នែកជាមធ្យោបាយពង្រីកពង្រឹងនូវមិត្តភាពសាមគ្គីភាពរវាងសមាជិកមហាគ្រួសារគ្រូបង្រៀន ឬបើនិយាយជាទូទៅ ជាការរឹតបំណងសាមគ្គីភាពរវាងប្រជាជននៃខេត្តទាំងពីរផង ហើយមួយផ្នែកទៀតជាសកម្មភាពមួយញុំាងបរិយាកាសនៃទិវាសិទ្ធិមនុស្ស ឲ្យមានសភាពរីករាយយ៉ាងមហោឡារិកផង ។

រីឯលទ្ធផលមានដូចខាងក្រោមនេះ :

| | | | | | | |
|---|---|---|---|---|---|---|
| ១— | កីឡាកូនឃ្លីលើតុ | : | មិត្តខាងស្ទឹងត្រែងឈ្នះ | ២ | ទល់នឹង | ១ |
| ២— | កីឡាបាល់ទះ | : | មិត្តខាងក្រចេះឈ្នះ | ២ | ទល់នឹង | ០ |
| ៣— | កីឡាបាល់ទាត់ | : | មិត្តខាងក្រចេះឈ្នះ | ៤ | ទល់នឹង | ១ |

● កាលពីថ្ងៃទី ១៤ ធ្នូ នៅអនុវិទ្យាល័យទេពប្រណម្យ មានបើកសម័យប្រជុំសមាជិកចាស់ថ្មី នៃសមាគមសាស្ត្រាចារ្យខ្មែរ ក្រោមអធិបតីភាពនៃមិត្ត លី-គិមអ៊ី ចាងហ្វាងអនុវិទ្យាល័យ ដើម្បីនឹងធ្វើការជ្រើសរើសតំណាង ស.ស.ខ. ប្រចាំអនុវិទ្យាល័យនេះ ។

ក្រោយពីបានពិភាក្សា ប្តូរយោបល់គ្នាអស់ពេលដ៏យូរ អង្គប្រជុំបានមូលមតិគ្នាជាឯកច្ឆន្ទថាត្រូវតែទុកដំណែងជាតំណាង ស.ស.ខ. នេះជូនមិត្តចាងហ្វាង ។ ប៉ុន្តែ ដោយមិត្តមានភារៈចាត់ការសាលាច្រើនពេក ដូចនេះត្រូវជ្រើសរើសតំណាងរងម្នាក់ដើម្បីនឹងជួយធ្វើការមិត្តក្នុងកិច្ចការបំរើសមាគម ។

មិត្ត កាន់-វ៉ុន ក៏ត្រូវបានអង្គប្រជុំជ្រើសរើសឲ្យធ្វើជាតំណាងរងនៃ ស. ស. ខ. ប្រចាំអនុវិទ្យាល័យទេពប្រណម្យ ។

មិត្តចាងហ្វាងបានថ្លែងអំណរគុណដល់អង្គប្រជុំ ចំពោះការទុកចិត្តលើរូបមិត្តឲ្យនៅធ្វើជាតំណាង ហើយមិត្តបានឆ្លៀតឱកាសនោះពន្យល់អំពីគោលបំណងរបស់ ស. ស. ខ. យើង ចំពោះសមាជិកដែលទើបនឹងសុំចូលថ្មី ព្រមទាំងបានអំពាវនាវដល់សមាជិកទាំងអស់ឲ្យបង់វិភាគទានប្រចាំខែរបស់ខ្លួនឲ្យបានទៀងទាត់ ដើម្បីជួយផ្គត់ផ្គង់សមាគមក្នុងការចំណាយជាចាំបាច់ផ្សេងៗ ។

នៅពេលជាមួយគ្នានោះ តាមការស្នើយោបល់ពីមិត្តចាងហ្វាង អង្គប្រជុំបានស្រុះស្រួលមូលមតិគ្នាថានឹងធ្វើ ពិកនិក (Pique Nique) នៅថ្ងៃទី ១៩ ធ្នូ នៅវត្តអង្គសិរី ដើម្បីធ្វើឲ្យសមាជិក ស.ស.ខ. និងសហការីនៅអនុវិទ្យាល័យទាំងអស់មានការស្និទ្ធស្នាលនឹងគ្នាម្យ៉ាង ហើយម្យ៉ាងទៀត ដើម្បីរឹតចំណងមិត្តភាពដែលមានរួចមកហើយឲ្យបានមាំឡើងទៀត ។

● កាលពីថ្ងៃទី ១៨-១៩ ធ្នូ ១៩៦៤ នៅក្នុងបរិវេណអនុវិទ្យាល័យ ព្រែកសណ្តែក មានបើកការប្រកួតកីឡាជាមិត្តភាពមួយរវាងក្រុមបុគ្គលិកអនុវិទ្យាល័យស្ទឹង “កំពង់ចាម” នឹងក្រុមចម្រុះបុគ្គលិកអនុវិទ្យាល័យព្រៃដើមថ្នឹង រួមព្រែកសណ្តែក ក្នុងស្រុកស៊ីធរកណ្តាល ។

នៅពេលចប់ពិធីប្រកួតនាថ្ងៃទី ១៨ មានការរៀបចំពិធីជប់លៀងឧឡារិកមួយ ប្រកបដោយបរិយាកាសមេត្រីភាពស្និទ្ធស្នាល ក្នុងរង្វង់បុគ្គលិកទាំងបីគ្រឹះស្ថាន ហើយមានការប្តូរយោ-បល់ក្នុងកិច្ចសហប្រតិបត្តិការ និងការរឹតចំណងមេត្រីភាពជាទីកក់ក្តៅ ដោយគេសង្កេតឃើញជាអាទិ៍ លោក ថេង ស៊ី ចៅហ្វាយស្រុកស៊ីធរកណ្តាល មិត្ត កូវ គា ហេង មិត្ត ប៉ូច សេង មិត្ត ង៉ែ ស៊ុន លី និងមិត្ត លាង ស៊ុន ចាងហ្វាងអនុវិទ្យាល័យព្រែកសណ្តែក - ព្រៃដើមថ្នឹង-ស្ទួង “ កំពង់ចាម ” និងដីហែ "កំពង់ចាម" ឡើងម្តងម្នាក់ កាន់ទេគ្លាសទសព្ទ ព្រមដោយការទះដៃអបអរនៃ សាស្ត្រាចារ្យ និងបុគ្គលិកជិត ១០០ នាក់ ។ បន្ទាប់ពេលចប់ការប្រកួតបាល់ទាត់ ដោយបានលទ្ធផល ពីរទល់នឹងពីរ នៅពេលព្រឹកថ្ងៃទី ១៩ មិត្តអនុវិទ្យាល័យស្ទួង បានលាចេញដំណើរពីព្រែកសណ្តែកទាំងក្តីអាល័យ និងយកទៅនូវអនុ-ស្សាវរីយជាទីមនោរម្យ ។

● កាលពីថ្ងៃ ២៣ ធ្នូ ១៩៦៥ កន្លងទៅនេះ លោក ខៀវ កុមារ អគ្គហេរញ្ញិក ក្នុងនាមគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ បានអញ្ជើញទៅដង្ហែសពលោកសោម តាំង អឿន ត្រូវជាឪពុករបស់លោក តុំ ស៊ុនដារ៉ា សាស្ត្រាចារ្យអនុវិទ្យាល័យស្ទួង ដែលធ្វើឈាបនកិច្ចនៅវត្តឧណ្ណាលោម វេលាម៉ោង ៣ រសៀល ។

សមាជិកទាំងអស់នៃគណៈកម្មាធិការនាយក សូមមិត្ត ស៊ុនដារ៉ា ទទួលនូវការចូលរួមមរណទុក្ខនេះជាមួយមិត្តផង ។

● យើងមានសេចក្តីរីករាយ ដោយបានដំណឹងជាចុងក្រោយបំផុត ថាមិត្ត ចាប់ ស៊ុប ចាងហ្វាងអនុវិទ្យាល័យឆ្លូង (ក្រចេះ) ដែលជាតំណាងនៃ ស.ស.ខ.យើង ទើបនឹងបានរៀបអាពាហ៍ពិពាហ៍ជាមួយនាងកញ្ញា អ៊ី សូកណ្ណាត ។ ក្នុងពិធីនេះ មិត្តសមាជិកគណៈកម្មាធិការនាយកខ្លះនិងសមាជិកនៅភ្នំពេញជាច្រើនទៀតបានចូលរួមផង ។

យើងសូមប្រសិទ្ធិពរឲ្យគូស្រករថ្មីនេះ ជួបតែនឹងសុខសួស្តីសិរីមង្គលកុំបីឃ្លៀងឃ្លាតឡើយ ។

●

# មហាសន្និបាតសាមញ្ញ

# ស.ស.ខ. ឆ្នាំ 1965

សមាជិក មហាសន្និបាតកំពុងស្តាប់សេចក្តីរាយការណ៍
របស់គណៈកម្មាធិការនាយក ដោយផ្ទៀងផ្ទាត់



មហាសន្និបាតសាមញ្ញឆ្នាំនេះ បានបើកសម័យប្រជុំ នៅទីស្នាក់ការរបស់ខ្លួន ( ជាលើកទីពីរនៅទីនេះ ) កាលពីថ្ងៃចន្ទ ២៣ សីហា នៅម៉ោង ១៨ ក្រោមអធិបតីភាពរបស់មិត្ត កែ-សុខន ប្រធាន ។

អ្នកដែលបានអញ្ជើញចូលរួមមហាសន្និបាត ក្រៅពីសមាជិកនៃគណៈកម្មាធិការនាយកចេញ មានអស់មិត្តតំណាង ស.ស.ខ. តាមអគារនឹងក្រសួងផ្សេងៗ អស់មិត្តសមាជិកមួយចំនួននៅភ្នំពេញ ហើយនឹងអស់មិត្តមួយចំនួនទៀត ដែលជាសមាជិកនៃគណៈមេប្រយោគប្រឡងសញ្ញាបត្រលើកទីពីរ ។

•

**ប្រធាន**

មិត្ត កែ សុខន បើកសម័យប្រជុំដោយគូសបញ្ជាក់អំពីសារៈសំខាន់នៃសមាជិកយើងឡើងវិញ ហើយនឹងការចំរើនលូតលាស់ដែលសមាគមយើងបានជួបប្រទះឥតឈប់ឈរក្នុងរយៈមួយឆ្នាំកន្លងទៅ ។

**អនុប្រធាន**

មិត្ត មាស ឌឹម អនុប្រធាន ដែលបានទទួលសម្តែងពីមិត្ត កែ សុខន បានធ្វើសេចក្តីរាយការណ៍ខាងផ្លូវចិត្តមួយយ៉ាងក្បោះក្បាយ ។ បន្ទាប់ពីបានរំលឹកឡើងវិញនូវការរួមចំណែករបស់សមាគមយើង ក្នុងការដង្ហែព្រះរាជនយោបាយរបស់សម្តេចឪមក មិត្តអនុប្រធានបានបញ្ជាក់នូវទំហំរបស់សមាគមយើង ហើយនឹងសកម្មភាពនៃសមាគមយើង ក្នុង « ចលនាអក្ខរកម្ម » ក្នុងចលនាខេមរនីយកម្មនៃការសិក្សាជាតិយើង ក៏ដូចជាក្នុងការទាក់ទង ជាមួយសមាជិកនៅរាជធានីនឹងនៅតាមខេត្តៗ

**អគ្គលេខាធិការ**

នៅក្នុងសេចក្តីរាយការណ៍សកម្មភាពរបស់ខ្លួន មិត្ត ទីវ អុល អគ្គលេខាធិការបានពណ៌នា :

## ១. អំពីការងាររបស់គណៈកម្មាធិការនាយក

— ក្នុងការទាក់ទងសមាជិកឲ្យបានជិតស្និទ្ធ ប្រយោជន៍នឹងបំរើឲ្យបានជិតដល់ ស្របទៅតាមបណ្តាំនៃមហាសន្និបាតឆ្នាំ ១៩៦៤ ដូចជាការទៅសាកសួរសុខទុក្ខមិត្តនៅមន្ទីរពេទ្យ ហើយនិងការឆ្លើយតបនឹងសំណូមផ្សេងៗ របស់មិត្តជាដើម ។

— និងក្នុងការពង្រីកសមាគម មានការតាំងសៀវភៅនិងការសូមដីសង់ទីស្នាក់ការជាដើម ។

## ២. អំពីការរួមចំណែកលំអការសិក្សាជាតិ

ដោយជំរុញនូវគំនិតខេមរនីយកម្មនៃការសិក្សា និងចូលរួមក្នុង « ចលនាអក្ខរកម្ម » ។

## ៣. អំពីការទាក់ទងជាមួយនឹងឥស្សរជន ហើយនឹងសមាគមឯទៀតៗ

ហើយក៏បានបំផុសឡើងនូវបញ្ហាសំខាន់ៗមួយចំនួន ដើម្បីជូនមហាសន្និបាតសំរេច ( សូមអានអត្ថបទ ទៅខាងក្រោយ ) ។

### អគ្គហិរញ្ញិក

មិត្ត ឡឹក វ៉ន អគ្គហេរញ្ញិកបានជំរាបអង្គប្រជុំថា ហិបប្រាក់របស់យើង មានស្ថានភាពនឹងនជាមធ្យម ប៉ុន្តែមិត្តបានបញ្ជាក់ថា នៅមានមិត្តតំណាងជាច្រើនដែរ ដែលពុំទាន់បានប្រមូលភាគទានផ្ញើមកគណៈកម្មាធិការនាយក ហើយមិត្តក៏បានអំពាវនាវសូមឲ្យមិត្តទាំងនោះរួសរាន់បំបាត់ការយឺតយ៉ាវរបស់ខ្លួន (សូមអានតារាងលេខស្តីអំពី ចំណូល ចំណាយ និងសំណល់ ទៅខាងក្រោយ ) ។



លុះការបោះឆ្នោតជ្រើសរើសសមាជិក គ.ន. ថ្មី បានប្រព្រឹត្តទៅរួចហើយ (សូមមើលលទ្ធផល នៅខាងក្រោម) ការពិភាក្សាអំពីសេចក្តីរាយការណ៍ (ខាងផ្លូវចិត្ត ខាងសកម្មភាព និងខាងហិរញ្ញវត្ថុ) ក៏ចាប់ផ្តើម ។

●

## ការពិភាក្សា

មានមិត្តជាច្រើននាក់ បានឡើងធ្វើអនុគមន៍ ដោយចាប់អារម្មណ៍សរសើរអំពីការខិតខំរបស់គណៈកម្មាធិការនាយក ក្នុងការទាក់ទងនឹងសមាជិក ក្នុងការផ្តល់វិភាគទានដល់ខេមរនិយកម្មនៃការសិក្សា និងក្នុងការពង្រីកឥទ្ធិពលនៃសមាគមដោយបង្កើនការទាក់ទងជាមួយនឹងឥស្សរជនជាន់ខ្ពស់របស់ជាតិ ហើយនឹងសមាគមសិក្សាបរទេស ។ មានមិត្តខ្លះបានសំដែងសេចក្តីពេញចិត្តរបស់ខ្លួន ចំពោះការផ្សាយមេរៀនផ្សេងៗ ជាភាសាខ្មែរ ដោយមិត្ត ម៉ៃ លន់ មិត្ត មាស ឌឹម មិត្ត ឡឹក រិន ហើយសូមឲ្យទស្សនាវដ្តីយើង បន្តការនេះតទៅទៀត ហើយឲ្យបានកាន់តែទៀងទាត់ឡើង ។ ឆ្លៀតឱកាសនោះ មិត្ត ធុច រិន បានធ្វើសំណូមឲ្យមិត្តទាំងឡាយ ចូលរួមចំណែកក្នុងការនិពន្ធអត្ថបទ ឲ្យបានសកម្មជាងនេះថែមទៀត ។ អត្ថបទរបស់មិត្ត អាចចូលក្នុងផ្នែកណាក៏បាន : — អត្ថបទសំខាន់ស្តីអំពីការសិក្សាក្នុងប្រទេស ឬនៅបរទេស — ផ្នែកវប្បធម៌ — វិទ្យាសាស្ត្រនិងសិល្បៈ — ជីវភាពមិត្តយើង — សរជួងសាលា — អត្ថបទនិងឯកសារ — រឿងកំសាន្តខ្លីៗ — គំនូរកំប្លែងសួត — ពាក្យខ្លែង... ។

●

### លទ្ធផលនៃការបោះឆ្នោត

| | | |
|---|---|---|
| មិត្ត មាស ឌឹម | 62 | សម្លេង |
| — ទីវ អុល | 68 | — |
| — កែ គឹមហ្វួត | 61 | — |
| — ធុច រិន | 64 | — |
| — ណាង ហាប់អាន | 60 | — |
| — ខៀវ កុមារ | 67 | — |
| — ទេស សាភ៉ុន | 43 | — |
| — គង់ សុគុណ | 50 | — |
| — អ៊ុំ ភីន់ផិន | 49 | — |

**ប្រឹក្សា**

— សូ ណែម
— ឡឹក រិន
— អ៊ុល បគូ

# សេចក្ដីសំរេចចិត្ត

មហាសន្និបាត ក្រោយដែលបានពិភាក្សាអស់ពេលដ៏យូរមក បានសំរេចដាច់ខាតនូវបញ្ហាដូចតទៅ :

## I. ញត្តិ

ធ្វើញត្តិមួយច្បាប់ថ្វាយសម្ដេចព្រះបិតាសិក្សាធិការជាតិ មុនព្រះពជដំណើរទៅកាន់ប្រទេសបារាំង និងប្រទេសសង្គមនិយមមួយចំនួន (តាមគំនិតណែនាំ នៃមហាសន្និបាត– សូមអានអត្ថបទនៅខាងមុខ) ។

## II. ១. ខេមរនីយកម្ម

សូមឲ្យ ស.ស.ខ. យើងចូលរួមឲ្យសកម្មក្នុងខេមរនីយកម្មនៃការសិក្សាជាតិ មានការជូនយោបល់តាមអត្ថបទ ការផ្សាយការពិសោធន៍ពីបរទេស និងការផ្សាយមេរៀនផ្សេងៗ ជាភាសាខ្មែរជាដើម ។

### ២. តំណាងរង

– សូមឲ្យតំណាងទាំងឡាយ ជ្រើសរើសតំណាងរងម្នាក់សំរាប់ជួយការងារខ្លួនៗ

– មិត្តតំណាងរងអាចបើកសំបុត្រសមាគម ហើយចាត់ចែងការខ្វះខួសតំណាងដើម្បីជៀសវាងការយឺតយូរ ។

### ៣. អតីតនិស្សិត–សាស្ត្រាចារ្យ

– សូមឲ្យមិត្តសាស្ត្រាចារ្យ រាប់រកមិត្តដែលទើបតែនឹងចេញពីមហាវិទ្យាល័យគរុកោសល្យទៅឲ្យបានរាក់ទាក់ ហើយសូរនាំឲ្យចូល ស.ស.ខ. ។

– សូមមិត្ត ដែលបានចូល ស. ស. ខ. តាំងតែពីមហាវិទ្យាល័យគរុកោសល្យមកសួរនាំរក ស.ស.ខ. ក្នុងអគារដែលមិត្តចូលទៅបង្រៀន ហើយសូមចុះឈ្មោះជាថ្មីផង ។ – បើមិត្តចង់បានបណ្ណសមាជិកថ្មី សូមផ្ញើរូបថតមួយសន្លឹកនឹងលេខបណ្ណ និ-សាស្ត្រា.របស់មិត្តមកគណកម្មាធិការនាយក ។

### ៤. សាលាគរុវិជ្ជាជាន់ខ្ពស់

សូមឲ្យ គ.ន. ធ្វើអន្តរាគមន៍ សូមឲ្យមិត្តសាស្ត្រាចារ្យទាំងឡាយណាដែល បានបំពេញការបាន ៣ ឆ្នាំមកហើយ មានសិទ្ធិចូលប្រឡងជាមួយនឹងសាស្ត្រាចារ្យដែលមានសញ្ញាបត្រ « Propédeutique » ផង ។

### ៥. ជីវភាព

— សូមឲ្យ គ.ន. តាមសួរអំពីការផ្អាកទុកនូវប្រាក់បំណាច់គ្រួសារ (សូមអានពត៌មានថ្មីនៅខាងក្រោយ) ។

— សូមឲ្យ គ.ន. ធ្វើអន្តរាគមន៍ជាមួយក្រសួងមានសមត្ថកិច្ច ឲ្យបានបើកប្រាក់ប្រឡងសិក្សាឲ្យបានឆាប់រហ័ស ។

### ៦. ថ្ងៃកំណើតស.ស.ខ.

សូមឲ្យ គ.ន. ស៊ើរើឯកសារចាស់ៗ ហើយជ្រើសរើសយកថ្ងៃណាមួយ ជាថ្ងៃកំណើតរបស់សមាគមយើង ។

## III. សាមគ្គីភាព

១. សូមឲ្យ គ.ន. រៀបចំ ដំណើរកំសាន្តមួយទៅគិរីរម្យនៅថ្ងៃអាទិត្យ 29-8-65

២. រឿងពិធីជប់លៀង ជាប្រពៃណីរបស់សមាគម ត្រូវធ្វើនៅថ្ងៃពុធ 25-8-65 នៅបដិសណ្ឋារមណ្ឌលនៃសមាគម ប.ស.ខ. ។

មិត្តសមាជិកទាំងឡាយ បានពិភាក្សាអំពីបញ្ហាទាំងពួងយ៉ាងសកម្ម ក្នុងគំនិតយោគយល់គ្នាដើម្បីឆ្ពោះទៅរកសេចក្តីចំរើនរួម ហើយមហាសន្និបាតក៏បានចប់សព្វគ្រប់នៅម៉ោង ២១,១៥ នាទី ក្នុងបរិយាកាសសាមគ្គីជិតស្និទ្ធយ៉ាងក្រៃលែង ។

## សេចក្ដីរាយការណ៍សកម្មភាព

ទីវ អុល

មិត្តទាំងឡាយ

ឆ្នាំកន្លងទៅនេះប្រកបទៅដោយព្រឹត្តិការណ៍ជាច្រើន ដែលផ្ដល់នូវផលល្អដល់ប្រទេស និងប្រជាជាតិយើង ។ ប្រជាជនយើងបានរួមគ្នាជាធ្លុងមួយដៃថ្លៃព្រះរាជបល្ល័ង្កនិងសម្ដេចព្រះប្រមុខរដ្ឋ ដើម្បីការពារបូរណភាពនិងអធិបតេយ្យភាពជាតិ ចំពោះកលឧបាយដ៏ឧក្រិដ្ឋនៃចក្រពត្តិអាមេរិកនិងបរិវារពទាំងខាងក្នុងទាំងខាងក្រៅ និងដើម្បីស្ថាបនាប្រទេសជាតិ ។ នៅលើវណសិរ្សសិក្សាធិការ សម្ដេចព្រះបិតាសិក្សាធិការជាតិ ទ្រង់បានណែនាំឲ្យកែទំរង់ការសិក្សានិងបើកចលនាអក្ខរកម្មទូទាំងប្រទេស ។

នៅក្នុងចលនារួមលើផ្ទៃប្រទេសយើងនេះ សមាគមយើងបានខិតខំផល់នូវវិភាគទានដោយអស់សមត្ថភាពរបស់ខ្លួន ស្របទៅតាមចរន្តនៃការវិវត្តិរបស់ជាតិនិងក្នុងក្របខណ្ឌនៃលក្ខន្តិកៈរបស់ខ្លួន ។ ដូចនេះហើយបានជាសមាគមយើងបានបិតនៅក្នុងលក្ខណៈការងារងាយស្រួល ហើយបានទទួលនូវលទ្ធផលគួរជាទីពេញចិត្ត ។

●

### I. ជីវភាពផ្ទៃក្នុងសមាគម

ដោយអនុលោមទៅតាមបណ្ដាំនៃមហាសន្និបាត ១៩៦៤ គ.នាយកបច្ចុប្បន្នបានខិតខំរឹតចំណងសាមគ្គីភាពរវាងមិត្តយើងយ៉ាងមមាញឹក ដោយបង្កើនការទាក់ទងគ្នាឲ្យបានជិតស្និទ្ធជាងឆ្នាំមុនទៀតទៀត ។

- ក្រោយបរិវេសនកាលប្រមាណពីរខែ បញ្ជីជំរឿនក៏បានផ្ញើទៅគ្រប់អគារមធ្យមសិក្សា; បន្ទាប់មក សេចក្ដីរំលឹកក៏បានផ្ញើទៅជាញឹកញាប់ថែមទៀត ។ ដូចនេះហើយបានជាគេអាចសង្កេតឃើញដោយពេញចិត្តថា សមាជិកយើងបានឡើងចំនួនពី ៨០០ កាលពីឆ្នាំមុនមកដល់ ១.៣០០ ក្នុងឆ្នាំនេះ !

- ការសាកសួរសុខទុក្ខ មិត្តយើងតាមសំបុត្រក្ដី ដោយផ្ទាល់ខ្លួននៅមន្ទីរពេទ្យក្ដី ពេញក្ដី បានបង្កើនឡើងទៀត រីឯការចូលរួម ជួយឧបត្ថម្ភក្នុងកិច្ចរវល់ផ្សេងៗ (អាពាហ៍ពិពាហ៍ សំរាលកូន . . . ) ក៏កាន់តែចំរើន ។ តាមការអំពាវនាវរបស់ គ.ន.ជាហូរហែមក គំនិតភាតរភាពនេះក៏បានរីកពេញជ្រួតជ្រាបនៅក្នុងមជ្ឈដ្ឋានមិត្តយើងជាច្រើនមាននៅអនុវិ. សាលាលេខ ៩ វិទ្យា. កំពង់ធំជាដើម (មិត្ត ទីវ-អុល អានបញ្ជីមិត្តដែលគ.នាយកបានទៅសាកសួរនឹងជួយឧបត្ថម្ភ ) ។

- គ.នាយកបានប្រតិបត្តិតាមសំណូមដែលមិត្តយើងជាច្រើនបានផ្ញើមកតាមលិខិតក្ដី បានប្រាប់ផ្ទាល់មាត់ក្ដី ។
  - មានការសាកសួរនឹងស្នើយោបល់ដល់ក្រសួងមានសមត្ថកិច្ច អំពី «Certificat de cessation de paiement» ;
  - ការប្រមូលប្រធានវិញ្ញាសាប្រឡងផ្សេង ៗ ចុះទស្សនាវដ្ដី ;
  - ការចុះផ្សាយមេរៀនដើម្បីត្រាះទៅរកខេមរនីយកម្មនឹងដើម្បីសំរួលការបង្រៀនរបស់មិត្តយើងជាដើម ។

- លក្ខន្តិក:កែទំរង់ក៏បានយកទៅដំកល់ ។

- ទស្សនាវដ្ដីចេញបាន៤លេខតាមគំរោងការ ប៉ុន្តែចំពោះព្រឹត្តិបត្រពត៌មានគណ:កម្មាធិការនាយកសំរេចថានឹងចេញតែនៅពេលណាចាំបាច់ (គឺគ្មានភាពទៀងទាត់ដូចមុនទៀតទេ) ។

● គ.នាយកបានសំរេច ការតាំងសៀវភៅ សួរៀតជាភាសាបារាំងនៅទីស្នាក់ការរបស់ខ្លួន ពីថ្ងៃ១៥ ដល់ថ្ងៃ ២៥ មិថុនា ជាហេតុដែលធ្វើឲ្យបណ្ណាល័យយើងកើនសៀវភៅចំនួនជាង ១០០ ក្បាលទៀត ។ កិច្ចការរៀបចំពិធីនេះបានធ្វើឲ្យមិត្តគ.នាយក និងមិត្តខ្លះនៅភ្នំពេញមានការរវល់ជាច្រើន ជាប្រកពមួយនាំឲ្យសាមគ្គីភាពយើងកាន់តែបានជិតស្និទ្ធមួយកំរិតឡើងទៀត ហើយកិត្តិសព្ទ ស.ស ខ. យើងបានរន្ទឺឡើងមួយកំរិតទៀត ។ និស្សិតនិងបញ្ញវន្តគ្រប់មជ្ឈដ្ឋានបានមកអានសៀវភៅដែលយើងតាំងនោះ ។

● ម្យ៉ាងទៀត ដំណាងនៃគ.នាយកបីនាក់ (មាស ឌឹម កែ គឹមហួត ទីវ អុល) បានទៅ ស្ទូមដី នៅបូរីគីរីរម្យមួយកន្លែងដើម្បីនឹងសង់ទីសំណាក់ទៅអនាគត ។

●

## II. ចំពោះបញ្ហាសិក្សាធិការជាតិ

ក្រៅពីសកម្មភាពរឹតចំណងសាមគ្គីភាពហើយនឹងជួយឧបត្ថម្ភគ្នាទៅវិញទៅមក សកម្មភាពសំខាន់មួយទៀតរបស់សមាគមយើង គឺការផ្ដល់នូវវិភាគទានរបស់ខ្លួនក្នុងការធ្វើឲ្យសិក្សាធិការជាតិកាន់តែបានចំរើននឹងប្រសើរឡើង ហើយដោយចំពោះ គឺសំរេចការកែទំរង់ដែលសម្ដេចឪទ្រង់បានត្រួសត្រាយរួចមកហើយ ។

ក្នុងគំនិតនេះ គ.នាយកយើងបានធ្វើសកម្មភាពផ្សេង ៗ ដូចជា :

១. បានផ្ញើញត្តិមួយច្បាប់ ( ថ្ងៃ 23-12-64 ) ថ្វាយសម្ដេចព្រះបិតាសិក្សាធិការជាតិដើម្បីនឹង គាំទ្រនូវព្រះវិបារណៈកែទំរង់កម្មវិធីសិក្សាជាតិ ដែលព្រះអង្គទ្រង់បានប្រោសប្រទានក្នុងឱកាសប្រជុំការងារក្នុងព្រះបរមរាជវាំង កាលពីថ្ងៃ 13-12-65 ។

— ចំពោះញត្តិនេះ ទ្រង់បានបញ្ជាឲ្យសហជីវិន ចៅ សេង ឆ្លើយតប ( 4-1-65 ) ។

២. បានផ្ញើលិខិត (ថ្ងៃ 23 - 12 - 64) ជូនសហជីវិន ទៅសេង ប្រធានគណៈកម្មាធិការកែទម្រង់កម្មវិធីសិក្សា ដើម្បីនឹងបញ្ជាក់នូវគំនិតសហប្រតិបត្តិការ របស់ ស.ស.ខ. យើង ។

៣. បានចុះទស្សនាវដ្តី នូវអត្ថបទណែនាំបញ្ចេញផ្សាយនូវគំនិតខេមរនីយកម្ម តាមអត្ថបទយើងក្ដី តាមសេចក្ដីកត់ហេតុ នៃការប្រជុំការងាររបស់គណៈកម្មាធិការជាតិខាងការកែទម្រង់ក្ដី តាមការពិសោធន៍នៃរបៀបសិក្សានៅប្រទេសនានាក្ដី ។

— ឯមេរៀនផ្សេង ៗ ជាពិសេស មេរៀនប្រវត្តិវិទ្យាក៏បានចុះផ្សាយជាហូរហែមកដែរ ។

៤. សមាគមយើងបាន បើកថ្នាក់រៀន មួយនៅទីស្នាក់ការរបស់យើងដើម្បីនឹងបង្រៀនជនមិនចេះអក្សរ ។ ពេលចូលរៀន មានសិស្សជាង ២០ នាក់; សព្វថ្ងៃនេះសិស្សដែលមករៀនទៀងទាត់ ចំនួន ១២ នាក់ ។ គេចេះអាន ចេះសរសេរនឹងចេះធ្វើលេខបន្តិចបន្តួចហើយ ។ សម័យប្រឡង នឹងបើកតាមកាលគួរ ។

## III. ការទាក់ទងជាមួយនឹងឥស្សរជនខ្មែរ ហើយនឹងសមាគមដទៃ

ក្នុងវិស័យនេះ សមាគមយើងបានបន្តហើយបង្កើននូវការទាក់ទងដែល ស.ស.ខ ធ្លាប់បានធ្វើជារៀងរហូតមកហើយ ។

### ១. សម្ដេចព្រះមហាក្សត្រិយានីព្យាបាលព្រះរោគ

— គណៈកម្មាធិការនាយក បានផ្ញើទូរលេខមួយច្បាប់(25 - 3 - 65) ថ្វាយសម្ដេចព្រះមហាក្សត្រីយានី ក្នុងឱកាសដែលព្រះអង្គទ្រង់កំពុងតែព្យាបាលព្រះរោគនៅប្រទេសបារាំង ។

— ព្រះអង្គទ្រង់បានព្រះរាជទានឲ្យសម្ដេច ប៉ែន នុត ឆ្លើយតបមកយើងវិញ ។

២. ក្នុងឱកាសឆ្នាំថ្មី យើងបានផ្ញើ :

១. ទូរលេខមួយច្បាប់ (10-4-65) ថ្វាយព្រះពរឆ្នាំថ្មី ចំពោះសម្ដេចព្រះមាតាជាតិ នាក្រុងប៉ារី

— ព្រះអង្គទ្រង់បញ្ជាឲ្យសម្ដេច ប៉ែន នុត ឆ្លើយតប (17-4-65)

២. លិខិតមួយច្បាប់ថ្វាយព្រះពរសម្ដេចព្រះប្រមុខរដ្ឋ

៣. — ព្រះសំឃរាជថ្នាក់ទី ១

៤. — ព្រះសំឃរាជថ្នាក់ទី ២

— ព្រះអង្គទ្រង់បានឆ្លើយតបមកវិញ ។

៣ ចំពោះសហជីពអ្នកអប់រំចិន

— ក្នុងឱកាសដែលប្រទេសមហាមិត្តទី១ របស់យើង សាកល្បងដោយសំរេចជោគជ័យនូវគ្រាប់បែកបរមាណូទី ២ របស់ខ្លួន យើងបានផ្ញើលិខិតសរសើរនិងត្រេកអរមួយច្បាប់ចំពោះសហជីពអ្នកអប់រំចិន (20-5-65) ។

— ចំពោះលិខិតនេះ មិត្តយើងបានឆ្លើយតបមកវិញ កាលពីថ្ងៃ 2-7-65 ។

## IV. បញ្ហាខ្លះៗ

ក្នុងឆ្នាំដែលកន្លងទៅនេះ សមាគមយើងមានដំណើរទៅមុខគួរជាទីសោមនស្សហើយ ប៉ុន្តែនៅមានបញ្ហាខ្លះដែលមិត្តយើងគប្បីជួយដោះស្រាយឲ្យបានស្រួលផង ។

### ១. ការទាក់ទង

ចំពោះបញ្ជីជំរឿនសមាជិកដែលគ.ន.ផ្ញើទៅ មានមិត្តតំណាងភាគច្រើនបានឆ្លើយតបមកវិញដោយរួសរាន់ ប៉ុន្តែ ក៏នៅមានមិត្តមួយចំនួនទៀត ដែលរហូតមកទល់នឹងពេលនេះ នៅពុំទាន់បានឆ្លើយតបសោះ ។ ការនេះ បង្កើតជាការពិបាកមួយយ៉ាងធំចំពោះគ.ន.ក្នុងការទាក់ទងនឹងមិត្តយើង មានការផ្ញើទស្សនាវដ្ដីជាដើម ។ សូមអំពាវនាវ (...) ។

## ២. ការនិពន្ធមេរៀនប្រវត្តិវិទ្យា–ភូមិវិទ្យា

មិត្ត កែ គឹមហួត បានដកស្រង់កម្មវិធីថ្នាក់ទី ៣ – ៤ ផ្ញើទៅស្នើមិត្តយើងខ្លះឲ្យជួយនិពន្ធមេរៀនខាងលើ ១ ឬ ២ នាក់ ប៉ុន្តែមិនទាន់មានមិត្តណាម្នាក់ ឆ្លើយតបជាវិជ្ជមានមកវិញនៅឡើយសោះ ។

## ៣. ការបើកស្រោមសំបុត្រ

គ.ន.បានសង្កេតឃើញនូវការយឺតយ៉ាវខ្លះ ដែលបណ្ដាលមកពីការបើកស្រោមសំបុត្រ ដែលរហូតមកទល់នឹងពេលនេះ មានតែមិត្តតំណាងម្នាក់ប៉ុណ្ណោះមានសិទ្ធិ ។ គ.ន.សូមស្នើឲ្យមិត្តតំណាងរងបើកសំបុត្របានផង ហើយដោយថាហេតុចាត់ការផង ក្នុងករណីដែលមិត្តតំណាងមិននៅ ។

●

ក្នុងឆ្នាំនេះ អាស្រ័យអាកប្បកិរិយាដ៏ត្រឹមត្រូវរបស់យើង ដែលឈរតែលើប្រយោជន៍ជាតិ ប្រយោជន៍មហាជននិងប្រយោជន៍សមាជិក ហើយអាស្រ័យការខ្នះខ្នែងរបស់គ.ន.ផ្សំនឹងការទទួលខុសត្រូវរបស់មិត្តតំណាង និងមិត្តសមាជិកទាំងឡាយផង សមាគមយើងបានស្គាល់នូវជោគជ័យមួយគួរជាទីពេញចិត្ត ។ យើងសូមសង្ឃឹមថា ស.ស.ខ. យើង ក្រោមការដឹកនាំរបស់ គ.ន. ក្រោយនឹងកាន់តែប្រមូលបាននូវលទ្ធផលដ៏ប្រសើរថែមទៀតជាប្រាកដ ។

ជយោ សមាគមសាស្ត្រាចារ្យខ្មែរ !

ជយោ វប្បធម៌ជាតិ !

# សេចក្ដីរាយការណ៍ខាងហិរញ្ញវត្ថុ

ឡឹក វ៉ន

## ក. បំណូល :

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 1· | វិទ្យាល័យ | ព្រះអង្គឌួង | | | | | | 5. 830 រៀល |
| 2· | — | ព្រះស៊ីសុវត្ថិ | | | 1.660 | 2.160 | 1.080 | 4. 800 — |
| 3. | — | ព្រះសីហនុ | | | | 2.000 | 2.480 | 4. 480 — |
| 4. | — | កំពង់ធំ | 1.600 | 500 | 1.000 | 200 | 500 | 3. 800 — |
| 5· | — | ព្រះសុរិយោវង្ស | | 1.117 | 1.114 | 1.079 | 1.417 | 4. 817 — |
| 6· | — | ព្រះមុនីវង្ស | | | | 1.980 | 900 | 2. 880 — |
| 7. | — | ព្រះឧទ័យ | | 520 | 1.000 | 1.000 | 1.000 | 3. 520 — |
| 8. | — | បច្ចេកទេស (ភ្នំពេញ) | | | | | | 4. 000 — |
| 9. | — | សង្គមរាស្ត្រនិយម | | 1. 020 | 280 | 160 | 680 | 2. 140 — |
| 10. | — | រាស្ត្រនិយមព្រះសីហនុ (តាខ្មៅ) | | | | | | 1. 360 — |
| 11. | — | ព្រះសុរាម្រិត | | | | 1.305 | 1.250 | 2. 555 — |
| 12. | — | ឥន្ទ្រទេវី | | | 420 | 420 | 500 | 1. 340 — |
| 13. | — | សុរិយាវង្សទី ២ | | | | | | 2. 000 — |
| 14. | — | ព្រះហរិរក្សរាមា (ខ្មែរ - អង់គ្លេស) | | | | | | 450 — |
| 15. | — | ព្រះរាជសម្ភារ | | | | | | 2. 000 — |
| 16. | — | ព្រះមហាក្សត្រិយានីកុសមៈ | | | | | | 1. 120 — |
| 17. | អនុវិទ្យាល័យ | សន្តិភាព | | | 1. 140 | 320 | 500 | 1. 960 — |
| 18. | — | រាជបូជនីយកិច្ច | | | | | | 770 — |
| 19. | — | គន្ធបុប្ផា | | | | 1. 000 | 1. 470 | 2. 470 — |
| 20. | — | ស្ទឹងត្រង់ | | | | 700 | 1. 000 | 1. 700 — |
| 21. | — | ទូកមាស | | | | | | 1. 000 — |
| 22. | — | តាំងគោក | | | | 1. 560 | 400 | 1. 960 — |
| 23. | — | បច្ចេកទេស (កំពង់ចាម) | | | 3. 920 | 1. 000 | 800 | 5. 720 — |

| | | | |
|---|---|---|---|
| 24. អនុវិទ្យាល័យ | ព្រែកពោធិ | | 880 រៀល |
| 25. — | កំពង់ត្របែក | 2.560 + 1.860 | = 4.420 — |
| 26. — | ទេពប្រណម្យ | 340 + 920 | = 1.260 — |
| 27. — | ព្រៃដើមថ្នឹង | 1.020 + 420 | = 1.440 — |
| 28. — | រស្មីសោភ័ណ | 1.840 + 740 | = 2·580 — |
| 29. — | ព្រះនរោត្តម | 600 + 1.200 | = 1.800 — |
| 30· — | ស្ទួង | 2.500 + 2.900 | = 5.400 — |
| 31. — | ពាមជីកង | 1 107 + 332 + 474 | = 1.913 — |
| 32. — | នេតយ៉ង់ | | 560 — |
| 33. — | ពាភាំង | 800 + 160 + 420 | = 1.380 — |
| 34. — | បរិបូរណ៍ | | 100 — |
| 35 — | ផ្សារថ្មី | 1.340 + 560 | = 1.900 — |
| 36. — | ជម្ពូវ័ន | 200 + 600 | = 800 — |
| 37. — | សាលាលេខប្រាំ | 520 + 490 + 320 + 860 | = 2.190 — |
| 38. — | ព្រែកសណ្ដែក | 1.160 + 1.000 | = 2.160 — |
| 39. — | រតនគិរី | | 100 — |
| 40. — | ត្រាំកក់ | | 1.020 — |
| 41. — | កំពង់ក្ដី | | 690 — |
| 42. — | ទឹកឃ្លាំង | | 540 — |
| 43 — | ក្រូចឆ្មារ | | 3.540 — |
| 44 — | កោះកុង | | 1.000 — |
| 45. — | ព្រះមហាក្សត្រិយានីស៊ីសុវត្ថិកុសមៈ | | 930 — |
| 46. — | ព្រៃទទឹង | | 1.452 — |
| 47. — | ជ្ជូង | | 1.820 — |
| 48 — | ជ័យវរ្ម័ន ទី៧ | | 720 — |
| 49. — | ស្គន់ | | 1.240 — |
| 50 — | ឧដុង្គ | | 950 — |
| 51. មហាវិទ្យាល័យ | គរុកោសល្យ | 2.200 + 1.500 + 4.040 + 2.000 + 500 + 500 | = 10.740 — |

| | | |
|---|---|---|
| 52. ញ៉ោប មៅ | | 520 រៀល |
| 53. ទស្សនាវដ្ដីសាស្ត្រាចារ្យ | | 400 — |
| 54. ជួយ វី | | 100 — |
| | សរុប | **117.217** រៀល |

| | | |
|---|---|---|
| ១. ចំណាយ | ចំណាយទាំងអស់ | **89.523** — |
| | សំណល់ | **27.694** — |
| | ប្រាក់សល់ក្នុងហិបពីមុនមក | **80.563** — |
| គ. ប្រាក់មានក្នុងហិបសព្វថ្ងៃ | | **108.257** — |

ក្នុងប្រាក់ទាំងអស់នេះ យើងបានយកទៅទិញបណ្ណរតនាគារអស់ ៥០.០០០ រៀល ហើយគិតជាការប្រាក់ ៤% ។ ឯប្រាក់សល់ពីនោះ យកទៅផ្ញើនៅធនាគារខ្មែរខាងពាណិជ្ជកម្មគណនី ឡឹក វ៉ន លេខ D. 462 ពុំត្រូវបានការប្រាក់អ្វីទេ ។

ភ្នំពេញ, ថ្ងៃទី ១៧ សីហា ១៩៦៥

អគ្គហេរញ្ញិក : ឡឹក វ៉ន

●


**បណ្ណាគារ តាវ អ៊ី**

លេខ 443 មហាវិថីព្រះមុនីវង្ស ភ្នំពេញ មានសេចក្ដីរីករាយនឹងចុះថ្លៃ 20% ជូនសមាជិកនៃ ស.ស.ខ. យើង ដែលទៅទិញសៀវភៅនៅបណ្ណាគារនេះ ។

សូមបង្ហាញបណ្ណសមាជិក !

# បន្ថែម

បន្ទាប់ពីមហាសន្និបាត (23-8-65) មក គណៈកម្មាធិការនាយក ទើបតែនឹងបានទទួលពីតំណាងមិត្តយើង នូវភាគទានខ្លះទៀតដូចតទៅនេះ ៖

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | អនុវិទ្យាល័យ ជើងគ្នុក | ( កំពង់ចាម ) | | | 1.200 | 440 | 1000 | រៀល |
| 2 | — បរិបូណ៌ | ( កំពង់ឆ្នាំង ) | | | | | 200 | — |
| 3 | — កំពង់ចិន | ( កំពង់ធំ ) | | | | | 960 | — |
| 4 | — កោះទិន | ( តាកែវ ) | | | | | 700 | — |
| 5 | — សេរីមង្គល | ( រកាកោង ) | | | | | 1.110 | — |
| 6 | — ពារាំង | ( ព្រៃវែង ) | | | | | 500 | — |
| 7 | — ស្គន់ | ( កំពង់ចាម ) | | | | | 840 | — |
| 8 | — ព្រះសីហនុរាជ | ( ផ្សារថ្មី កណ្ដាល ) | | | | | 1.300 | — |
| 9 | — សាលាលេខប្រាំ | ( កំពង់ឆ្នាំង ) | | | | 480 | 460 | — |
| 10 | — ទឹកឃ្លាំង | ( កណ្ដាល ) | | | | | 720 | — |
| 11 | វិទ្យាល័យ សន្តិភាព | ( កំពង់ស្ពឺ ) | | | | 800 | 340 | — |
| 12 | — ព្រះអង្គឌួង | ( ព្រៃវែង ) | | | | | 3.000 | — |
| 13 | — ពញាយ៉ាត | ( ភ្នំពេញ ) | | | | | 500 | — |
| 14 | — សុរិយាវរ្ម័នទី ២ | ( សៀមរាប ) | | | | | 3.000 | — |
| 15 | — ព្រះមុនីវង្ស | ( បាត់ដំបង ) | | | | | 2.135 | — |
| 16 | — ព្រះរាជ័យ | ( តាកែវ ) | | | | | 1.000 | — |
| 17 | មហាវិទ្យាល័យវិចិត្រសិល្ប៍ | | | | | | 700 | — |
| 18 | មហាវិទ្យាល័យគរុកោសល្យ | | 300 | 300 | | 240 | 400 | — |
| 19 | អនុវិទ្យាល័យព្រែកសណ្ដែក | | | | | | 1.000 | — |
| 20 | — ព្រៃដើមថ្នឹង | | | | | | 500 | — |
| 21 | វិទ្យាល័យ សុរិយោវង្ស | | | | | | 1.595 | — |
| 22 | អនុវិទ្យាល័យ ស្ទឹងត្រង់ | | | | | | 368 | — |
| 23 | — ពាមជីកង | | | | | | 720 | — |

# ពិធីជប់លៀងថ្ងៃ 25-8-65

ជារៀងរាល់ឆ្នាំ គណៈកម្មាធិការនាយកនៃស.ស.ខ. តែងតែបានរៀបចំពិធីជប់លៀងជាប្រពៃណីមួយ ក្នុងឱកាសប្រឡងសញ្ញាបត្រលើកទី ២ ដើម្បីទឹងធ្វើបដិសណ្ឋារកិច្ចដល់មិត្តយើងដែលមកពីខេត្ត ក៏ដូចជាដើម្បីទឹងរឹតបំណងសាមគ្គីភាពរវាងមិត្តនៅខេត្តនឹងមិត្តនៅភ្នំពេញ ៗ ពិធីជប់លៀងឆ្នាំនេះ បានធ្វើឡើងពីរថ្ងៃក្រោយមហាសន្និបាត (គឺថ្ងៃ២៥.៨.៦៥ ) នៅលើព្រលានជាជំបូលនៃបដិសណ្ឋារមណ្ឌលនៃ “ សមាគមបុគ្គលិកសិក្សាខ្មែរ AMCEK ” បំកណ្ដាលរាជធានី ជាទីដែលមិត្តយើងមួយចំនួនធំបានស្នាក់អាស្រ័យនៅ ។



សភាពថ្មីនៃពិធីជប់លៀងឆ្នាំនេះ មិនមែនបិតនៅតែក្នុងចំនួនមិត្តយើងដែលមកចូលរួមដ៏កុះករ ( ប្រមាណ ១៥០ នាក់) នឹងក្នុងការលើកទីកន្លែងពីភោជនីយដ្ឋានចិនមកទីស្នាក់ការរបស់សមាគមសិក្សាតែប៉ុណ្ណោះទេ ប៉ុន្តែសភាពថ្មីបិតនៅជាពិសេសក្នុងការយកចិត្តទុក





ដាក់របស់មិត្តយើងពល់គ្នាក្នុងការចាត់ចែងពិធីនេះ តាមសមត្ថភាពរៀងៗខ្លួន ។ យើងនៅចាំបាននៅឡើយថា ក្រៅពីមិត្តក្នុងគ.នាយក មានមិត្តជាច្រើនទៀតដូចជា មិត្ត ម៉ុក មៅ សេង ប៊ុនថន ខែក ប៊ុន តាន់ ទ្រី យី យន់ ប៊ូ ម៉ក់ ព្រំសម្ផារ សាំងរិន ម៉ៃ លន់នេត សែប អ្នកស្រី ពាម យុស្យា មិត្តហូ ងៀ លី គិមអ៊ី ជាដើម បានខំខ្នះខ្នែងក្នុងការប្រមូលឈ្មោះនិងភាគទានរបស់មិត្តយើង ក៏ដូចជាក្នុងការរៀបចំខាងសម្ភារៈផ្សេងៗ ទៀត ។ ឯគណៈកម្មាធិការរៀបចំមាន មិត្ត អ៊ុល ចន្ទ ទទួលភារៈខាងម្ហូប មិត្ត ព្រំ សម្ផារ ខាងកែវចាន មិត្ត ទីវ អុល នឹងកែ គីម ហួត ខាងកេសជ្ជៈ មិត្ត ម៉ៃ លន់ ខាងតាក់តែងទីកន្លែង អ្នកស្រី ស ថៃ សេង ព្រំ សម្ផារ ទីវ អុល ម៉ៃ លន់ ខាងបន្ថែម មិត្ត ឈុប រិន ឈុម ហ៊ន់ថន គង់ សុគន្ធ ខាងរៀបចំតុកៅអី ។ គណៈកម្មាធិការជប់លៀងមានពិតមែន ប៉ុន្តែ ក្នុងពិធីជប់លៀង មិត្តទាំងឡាយបានធ្វើការ គ្រប់ៗគ្នា មើលទៅមិនដឹងជានរណា



ជាអ្នករៀបចំនរណាជាភ្ញៀវឡើយ ។ គេសាកសួរសុខទុក្ខគ្នា គេថ្លែងសេចក្តីនឹករលឹករកគ្នា គេនិយាយអំពីវិញ្ញាសាប្រឡង គេនិយាយអំពីកម្មវិធីសិក្សា គេនិយាយអំពីវប្បធម៌ជាតិ គេសើចលេងសប្បាយ...។ ពិធីជប់លៀងបានប្រព្រឹត្តទៅរហូតដល់ម៉ោង ២៣ ទើបចប់សព្វគ្រប់ក្នុងបរិយាកាសដ៏រីករាយ ។



# ដំណើរ

ពីរថ្ងៃបន្ទាប់ពីមហាសន្និបាត

ហើយបីថ្ងៃបន្ទាប់ពីពិធីជប់

លៀងមក គណៈកម្មាធិការនាយក ក៏បានរៀបចំដំណើរកំសាន្តមួយទៅគិរីរម្យ ។ មិត្តយើងទាំងប្រុសទាំងស្រី ប្រមាណជាង ៨០ នាក់ បានជិះរថយន្តដឹកនាំពីរធំមួយគូពមួយ ។

---

គណៈកម្មាធិការនាយក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមិត្ត កែ សុខន (អតីតប្រធាន) និងមិត្ត ឡឹក វ៉ន (អតីតអគ្គ–ហេរញ្ញិក) ដែលបានខិតខំផ្ដល់នូវវិភាគទានរបស់ខ្លួន ដោយអស់សមត្ថភាពជាយូរឆ្នាំមកហើយ ដើម្បីធ្វើឱ្យ ស.ស.ខ. យើងបានស្គាល់នូវសាមគ្គីភាព និងវឌ្ឍនភាព ។

# កំសាន្តនៅគិរីរម្យ 28-8-65

នៅគិរីរម្យ មិត្តយើងបានស្នាក់នឹងទទួលទានបាយថ្ងៃត្រង់ នៅវិមានសំរាកនៃ ក្រុមហ៊ុនសុរាគារខ្មែរ ដែលគណៈកម្មាធិការនាយកសូមខ្ចីបានពីរថ្ងៃ ។ ឆ្លៀតឱកាសនេះ ស.ស.ខ. សូមថ្លែងអំណរគុណជាថ្មីម្តងទៀតចំពោះលោកនាយកនៃ ក្រុមហ៊ុនសុរាគារខ្មែរ SKD ដែលមានសមានចិត្តចំពោះយើងជាខ្លាំង ។ កម្មវិធីក្រោយពេលបាយ គឺការដើរទស្សនាទីក្រុង ។ មិត្តយើងទាំងឡាយបានត្រឡប់មកដល់ទីស្នាក់ការវិញនៅវេលាម៉ោង ១៨ ប្រកបដោយសុវត្ថិភាព ដោយនាំយកមកជាមួយខ្លួន នូវទឹកចិត្តសាមគ្គីភាពនឹងអនុស្សាវរីយ៍ដ៏ល្អនៃបូរីយើង ។

ដំណើរកំសាន្តនេះទៀត ក្រៅពីបាននាំសេចក្តីសប្បាយរីករាយដល់មិត្តយើងទាំងអស់គ្នា ក៏បានធ្វើឲ្យមិត្តក្នុងគណៈកម្មាធិការនាយកកាន់តែបានរួមសាមគ្គីភាពគ្នាឡើងទៀត សាមគ្គីភាព នៅក្នុងការហត្ថកម្មនានា មានការរត់ផ្លូវរថយន្ត ការអាំងមាន់ការអាំងប្រហុក នឹងការដាំបាយមួយយប់ទាល់ភ្លឺ ។



# មិត្តតំណាង !

គណៈកម្មាធិការនាយកសូមសំដែងសេចក្ដីរីករាយ និងសរសើរដ៏ស្មោះ ចំពោះការខំប្រឹងប្រែងរបស់មិត្តក្នុងការបំរើសមាគមរបស់យើងរាល់គ្នានេះ ។ ថ្វីដ្បិតតែមានមិត្តខ្លះ ពុំទាន់បានផ្ញើដំណឹងផ្សេង ៗ និងផ្ញើភាគទានមកយើងនៅឡើយក៏ដោយ ក៏មិត្តភាគច្រើនបានផ្ញើពត៌មាននានា និងភាគទានមកដល់យើងហើយ ។

ក៏ប៉ុន្តែ ក្នុងការផ្ញើ **អាណត្តិប្រាក់ភាគទាន** មកគ.នាយក មិត្តខ្លះគ្រាន់តែចារថា :

"លោកប្រធានសមាគមសាស្ត្រាចារ្យខ្មែរ" តែប៉ុណ្ណោះ ។

ការសរសេរឈ្មោះបែបខាងលើនេះ នាំឱ្យមានការលំបាកច្រើន ពីព្រោះប៉ុស្តិ៍គេតម្រូវឱ្យយើងប្រគល់លក្ខន្តិកៈផង និងសំបុត្របញ្ជាក់ពីសាលាក្រុងផង ទើបគេព្រមបើកប្រាក់នោះឱ្យ ។

ដូចនេះ លើកក្រោយ ៗ សូមមិត្តមេត្តាផ្ញើ **អាណត្តិភាគទាន** ផ្សេងៗមកមិត្ត អគ្គហេរញ្ញិកយើង គឺ:

"លោក **ខៀវ** កុមារ ព្រឹទ្ធាចារ្យនៃមហាវិទ្យាល័យ វិទ្យាសាស្ត្រ និងបច្ចេកទេស ភ្នំពេញ"

សូមអរគុណ !

# ដំណឹងខ្លីៗ...

## សេចក្ដីស្នើ បង្កើត សមាគម មរណូបត្ថម្ភ
## ក្នុងផ្ទៃ ស.ស.ខ.

តាមសេចក្ដីស្នើរបស់មិត្ត ពៅ សុខឃិន នៃអនុវិទ្យាល័យព្រៃដើមថ្នឹង នឹងតាមសំណូមនៃសន្និបាតប្រចាំខែរបស់មិត្តនាយកនិងចាងហ្វាងនៃអគារសិក្សាខេត្តកណ្ដាលនៅតាខ្មៅក្នុងខែមុនៗនេះ គ.ន. បានសំរេចនៅក្នុងការប្រជុំមួយរបស់ខ្លួន

— ថានឹងបង្កើតឲ្យអង្គការមួយក្នុងផ្ទៃនៃ ស.ស.ខ. ដើម្បីនឹងជួយឧបត្ថម្ភសមាជិកនិងគ្រួសារនៅពេលមរណកាល ។

— ប្រគល់ភារៈរៀបចំសេចក្ដីព្រាងលក្ខន្តិកៈទៅមិត្ត គង់ សុគន្ធ និង ឌឹម ពិនជន ។

— ហើយថានឹងផ្ញើសេចក្ដីព្រាងលក្ខន្តិកៈនេះ ទៅសូមយោបល់ពីមិត្តយើងទាំងអស់ ដើម្បីនឹងតែងលក្ខន្តិកៈមួយជាសំរេច ។

ក្នុងពេលបណ្ដោះអាសន្ននេះ គ.ន. សំរេចថានឹងជួយឧបត្ថម្ភ ១.០០០ រៀលដល់សមាជិកអនិច្ចកម្ម ហើយ ៥០០ រៀលដល់ប្ដីឬប្រពន្ធសមាជិកអនិច្ចកម្ម (ដែលមិនមែនជាសមាជិក ស.ស.ខ.) ។

ដូចនេះ សូមមិត្តត្រៀមចាំជួយពិភាក្សា អំពីខ្លឹមសារនៃសេចក្ដីព្រាងលក្ខន្តិកៈនេះផង ដើម្បីសេចក្ដីចំរើនទាំងអស់គ្នា ។ យើងសូមបញ្ជាក់តាំងពីពេលនេះទៅ ថាមិត្តណាដែលបានចូលក្នុងសមាគមគរុមរណូបត្ថម្ភខាងសមាគមបុគ្គលិកសិក្សាហើយ បើចង់មកចូលខាង ស. ស. ខ. វិញក៏បាន មិនបាច់ក៏បាន ឬចូលទាំងពីរក៏បាន ។ ក្នុងករណីក្រោយនេះ មិត្តក៏នឹងបានទទួលផលពីរត្រួតដែរ !

# ការសន្ទនាជាមួយលោក ហ្យុង់ហ្គើរ

កាលពីល្ងាចថ្ងៃសុក្រ ៣ ធ្នូ ១៩៦៥ ម៉ោង ១៦ រសៀល នៅទីស្នាក់ការសមាគមបុគ្គលិកសិក្សា ( ភ្នំពេញ ) មានការជួបសន្ទនាមួយរវាង លោក អាល់ប៊ែរ ហ្យុង់ហ្គើរ (Albert Junger) មកពីស្រុកបារាំង ជាអគ្គលេខាធិការនៃសហពន្ធអន្តរជាតិនៃការសិក្សា (Ligue internationale de l'Enseignement) ជាមួយលោក សូ-ណៃម នឹង លោក ម៉ៃ លន់ ជាតំណាងសមាគមបុគ្គលិកសិក្សា នឹង លោក មាស ឌឹម នឹង ខៀវ កុមារ ជាតំណាងសមាគមសាស្ត្រាចារ្យខ្មែរ ។ បន្ទាប់ពីបានបញ្ជាក់ពីលក្ខណៈឯកជន នឹងគោលបំណងនៃ(Ligue internationale de l'Enseignement)មក លោក អាល់ប៊ែរ ហ្យុង់ហ្គើរ បានប្រាប់ថា សមាគមលោកបំរុងនឹងផ្ញើសេចក្ដីអញ្ជើញមកសមាគមគ្រូទាំង ២ ដើម្បីសូមបញ្ជូនគណៈប្រតិភូទៅមហាសន្និបាតគេ ដែលនឹងធ្វើនៅខែ កក្កដា ១៩៦៦ ខាងមុខ ។ គេនឹងទទួលឲ្យស្នាក់អាស្រ័យលើបន្ទុកគេ ប៉ុន្តែសោហ៊ុយដំណើរនៅលើយើង ។ គេច្រើនអញ្ជើញសមាគមសិក្សានៅអឺរ៉ុប-អាហ្វ្រិក នឹងអាមេរិកឡាទីន ។ មហាសន្និបាតគេបំរុងនឹងពិភាក្សាអំពីទិដ្ឋភាពគ្រប់យ៉ាងនៃការសិក្សា តាំងពីសិទ្ធិសិក្សានៅក្រៅជំនឿ អក្ខរកម្មរហូតដល់កីឡា - ការកំសាន្ត - ភាពយន្តនឹងទូរទស្សន៍ ។

ដោយយើងពុំទាន់ស្គាល់ច្បាស់នូវនិន្នាការនៃអង្គការរបស់គេផង ដោយហិបប្រាក់យើងក៏ខ្សត់ខ្សោយផង យើងប្រហែលមិនបញ្ជូនគណៈប្រតិភូទៅរួមក្នុងមហាសន្និបាតនេះទេ ។ ក្នុងឱកាសបដិសណ្ឋារកិច្ចនេះ សហជីវិន សូ-ណៃម បានជូនពានប្រាក់មួយជាអនុស្សាវរីយ៍ដល់កៀវយើង ។

កាលពីប៉ុន្មានថ្ងៃមុននេះ សហពន្ធអន្តរជាតិបានផ្ញើសេចក្ដីថ្លែងអំណរគុណមក ស.ស.ខ. យើង ព្រមទាំងបានអញ្ជើញយើងជាផ្លូវការផង ។ ស. ស. ខ. យើងប្រហែលជានឹងចាត់មិត្ត អៀង គន្ធសាគី ដែលនៅប្រទេសបារាំងស្រាប់ឲ្យចូលរួមមហាសន្និបាតនេះជាឯកជនៗ

●



## ពិធីជប់លៀងជូនដំណើរ មិត្ត យិន គឹមតេក

កាលពីខែមុននេះ មិត្ត យិន គឹមតេក ដែលទើបតែនឹងចេញពីមហាវិទ្យាល័យគរុកោសល្យ ទៅបង្រៀននៅវិទ្យាល័យព្រះគន្ធបុប្ផា (ព្រៃទទឹង កំពង់ចាម) បានត្រូវផ្លាស់ទៅបង្រៀននៅអនុវិទ្យាល័យកំពង់ត្របែក ព្រៃវែង ។

ក្នុងឱកាសបែកគ្នា មិត្តយើងនៅវិទ្យាល័យនោះ បានមូលមតិគ្នាធ្វើពិធីជប់លៀងមួយដើម្បីនឹងជូនដំណើរអ្នកដែលត្រូវចេញ ។ ម្ហូបអាហារតិចតួចស្តួចស្តើងមែនពិត ប៉ុន្តែទឹកចិត្តសាមគ្គីភាពមានព្រំដែនទូលំទូលាយណាស់ ។

មិត្តយើងគង់បានដឹងហើយថា នៅក្នុងវិទ្យាល័យព្រះគន្ធបុប្ផា ក្រោមកិច្ចឧបត្ថម្ភរបស់មិត្ត ឈឹម ទឹម (នាយក) ស. ស. ១. យើងបានស្គាល់នូវការរីកចំរើនពុំចេះឈប់ឈរ ។

•

## សារាចរបញ្ជាក់អំពីការផ្ញើប្រាក់បំណាច់គ្រួសារជូនបុគ្គលិកសិក្សា

Phnom-Penh, le 9 Septembre 1965

N°- 3.996 - Cpté/S.

LE MINISTRE D'ETAT CHARGE DE L'EDUCATION NATIONALE

A Monsieur le Directeur Général de l'Education

OBJET : Mandatement de l'allocation familiale et de différence de solde

REFERENCE: Ma lettre n° — 3238 cpté/S. du 5 Juillet 1965.

La deuxième paragraphe de ma circulaire citée en référence a mentionné que pour pallier à l'éventualité du manque de crédits pour le paiement du traitement du personnel pour les deux derniers mois du dernier trimestre de l'année en cours, le Département «décide de suspendre pour le moment le paiement des nouvelles allocations familiales et tout autre changement de

តទៅទំព័រ 54

# ការប្រែប្រួលនៅទ្វីបអាស៊ី




ថ្ងៃ ១៨ មេសា ១៩៦៥ នេះ ជាថ្ងៃខួបទី ១០ នៃសន្និសីទអាស៊ី–អាហ្វ្រិក ដែលបានបើកធ្វើឡើងនៅទីក្រុងបានឌុង (ឥណ្ឌូណេស៊ី) កាលពីថ្ងៃ ១៨ មេសា ១៩៥៥ ។ នៅពេលនោះ មានប្រទេសអាស៊ី–អាហ្វ្រិកចំនួនតែ ២៩ ទេដែលបានទៅចូលរួម ។

ដូចយើងឃើញស្រាប់ នៅពេលនោះ ប្រទេសអាហ្វ្រិកភាគច្រើនកំពុងតែត្រូវឋិតនៅក្រោមនឹមអាណានិគមនិយមនៅឡើយ ។

ក្នុងរយៈពេល ១០ ឆ្នាំកន្លងទៅនេះ មានប្រទេសអាស៊ី–អាហ្វ្រិកចំនួន ៣៥ បានទាមទារបាននូវឯករាជ្យរបស់ខ្លួនថែមទៀត តាមគំនិតនៃសន្និសីទបានឌុង ។

(ផែនទីស្រង់ពី «ពត៌មានប៉េកាំង» លេខ 17/1965)

# និង អាហ្វ្រិក ក្នុងឆ្នាំ 1955-1965




សព្វថ្ងៃនេះ នៅទ្វីបអាហ្វ្រិក មាននៅសេសសល់កំពែងរបស់លទ្ធិអាណានិគមនិយមតែមួយចំនួនដ៏តូចប៉ុណ្ណោះ ។ កំពែងទាំងនេះ ជាកំពែងដ៏ជាទីជាកចុងក្រោយបំផុតនៃជួររបស់វាហើយ ។ សព្វថ្ងៃ នៅក្នុងកំពែងទាំងនេះ អណ្ដាតភ្លើងនៃការតស៊ូប្រដាប់អាវុធ កំពុងតែឆេះឆាបឆេះយ៉ាងសន្ធោសន្ធៅទាំងឡើង ៗ បណ្ដេញពួកអ្នករកពនទចេញពីមាតុភូមិជាទីស្នេហា ។ មនុស្សចំនួន ១.៧០០ លាននាក់ក្នុងតំបន់ដ៏ធំធេងនៃទ្វីបអាស៊ី និងអាហ្វ្រិក កំពុងតែលើកជ្រោងនូវទង់សាមគ្គីភាព ប្រឆាំងនឹងពួកចក្រពត្តិនិយម ។ ដំណើររបស់គេបោះតែលឿនទៅមុខ គ្មានអ្វីអាចមកទប់បានឡើយ ។

តមកពីទំព័រ 51



situation du personnel survenu en cours de l'année au titre de différence de traitement résultant de la nomination, du versement, de la promotion, du reclassement et de la titularisation»

J'ai l'honneur de vous faire connaître que :

1°— Il ne s'agit nullement de la suspension de l'octroi des allocations familiales ni de la suppression desdites allocations.

2°— Il n'est non plus question de non mandatement de différence de solde et accessoires résultant de tout changement de situation du personnel.

3°— Ces allocations familiales et ces différences de solde et accessoires visées plus haut seront toujours mandatées au profit du personnel bénéficiaire intéressé au fur et à mesure que le Département dispose des crédits disponibles à cet effet.

4°— La circulaire du Département susvisée vise à éviter que les services procédant au mandatement des nouvelles allocations familiales et de différence de solde et accessoires des nouveaux changements de situation du personnel sur les crédits engagés dès le début de l'année, objet de l'état 3 lequel ne prévoit que les dépenses suivant la situation initiale du personnel au début de l'année, crédits délégués chaque trimestre pour ces fins, car toutes dépenses non prévues à l'état 3 doivent être l'objet de nouveaux engagements.

5°— Le mandatement des nouvelles allocations familiales et des différences de solde et accessoires pour les nouveaux changements de situation du personnel doit donc être subordonné aux nouveaux engagements de dépenses faits par le Département suivant les disponibilités budgétaires et au vu de la demande suplémentaire de crédits avec pièces justificatives règlementaires faites par les provinces intéressés.

Je vous prie en conséquence de vouloir bien communiquer d'urgence ces précisions à tout le personnel placé sous vos ordres et l'inviter à ne plus, à ce sujet, faire circuler des bruits tendancieux susceptibles de porter atteinte au renom du Département. Désormais, les auteurs de ces bruits s'ils venaient à être découverts, seraient exposés à des sanctions disciplinaires pour diffamation./—

Signé : SISOWATH SIRIK MATAK

•

បណ្ណាគារ វិជ្ជាសាកល
257 វិថីព្រះបាទសីហនុ ភ្នំពេញ

បណ្ណាគារ សុភមិត្រ
367 C ផ្លូវកម្ពុជាក្រោម ភ្នំពេញ

បណ្ណាគារទាំង ២ នេះ ទិញចុះថ្លៃ 10% ជូនមិត្តយើងដែលទៅទិញ
សៀវភៅខ្មែរ នៅបណ្ណាគារទាំងនេះ ហើយដែលបានបង្ហាញ
បណ្ណសមាជិកផង ។

# ប្រធានវិញ្ញាសា ប្រឡងមធ្យមសិក្សាបត្រ ភាគទី ២

## ក – ផ្នែក «ទស្សនវិជ្ជា» (PHILO) –សម័យថ្ងៃ ១៦–៨–៦៥

### ១. វប្បធម៌ឥណ្ឌា-ខ្មែរ (១ម៉ោងកន្លះ)

តាមការជ្រើសរើសនៃបេក្ខជន :

*ប្រធានទី១: ការសិក្សាវប្បធម៌ អរិយធម៌ឥណ្ឌា មានផលប្រយោជន៍ ដូចម្ដេចខ្លះ ចំពោះការសិក្សាវប្បធម៌ អរិយធម៌ខ្មែរ ? ចូរអធិប្បាយ ។*

*ប្រធានទី២: លទ្ធិវេទនិយមបានដឹកនាំមនុស្សឲ្យប្រព្រឹត្តនូវអំពើអ្វីខ្លះ ? នូវសីលធម៌អ្វីខ្លះ ?*

*ប្រធានទី ៣ : តើអ្វីខ្លះដែលជាគោលមូលដ្ឋានក្នុងព្រហ្មញ្ញនិយម ?*

### ២. ការតែងខាងទស្សនវិជ្ជា (៤ម៉ោង)

1er sujet.— D'Alembert recommandait comme bonne méthode de formation intellectuelle de « s'exercer aux démonstrations rigoureuses» et de « ne pas s'y borner ».

Expliquez et appréciez cette opinion.

2e sujet.— Expliquer la définition de la sensation donnée par ARISTOTE : « C'est l'acte commun du sentant et du senti ».

3e sujet.— Quelle est la signification et quelle est la valeur de ce conseil fréquemment donné : « Pensez par vous-mêmes»?

## ៣. វិទ្យាសាស្ត្រ ធម្មជាតិ (១ ម៉ោងកន្លះ)

1ᵉʳ sujet— La rétine: structure; rôle de ses différents constituants.

2ᵉ sujet.— La cellule végétale: sa structure et ses principaux constituants morphologiques.

3ᵉ sujet. – La chlorophylle: extraction, séparation des pigments, spectre d'absorption, rôle dans la photosynthèse.

## ៤. រូបវិទ្យា (១ ម៉ោងកន្លះ)

1ᵉʳ sujet.— Propriétés chimiques de l'éthylène.

Application numérique

On enflamme un mélange de 2 litres de l'éthylène et de 4 litres de chlore dans les conditions normales de température et de pression.

1°— Indiquer la nature et la masse des produits formés,

2°— Même question lorsqu'on abandonne ce mélange à la lumière diffuse.

On donne: H = 1 ; CI = 35, 5.

2ᵉ sujet.— L'acide acétique: propriétés chimiques et préparations.

Application numérique.

On ajoute peu à peu une solution de NaOH (solution normale) à 10 cm³ de vinaigre blanc additionné de phtaléine du phénol. La coloration rouge est obtenue lorsqu'on y verse exactement 13, 2 cm³ de NaOH. Déduire de ce dosage la masse d'acide acétique par litre de vinaigre.

3ᵉ sujet.— Chaleur et travail: expérience de Joule; calcul du travail transformé en chaleur; calcul de la quantité de chaleur Q.

Application numérique.

Un mobile de masse 10 tonnes est animé d'une vitesse de 45 km/h. Calculer l'énergie cinétique en joules de ce mobile.

On arrête brusquement ce moblie et on suppose que toute son énergie se transforme en chaleur, calculer cette quantité de chaleur.

★

## ខ. ផ្នែកគណិតវិទ្យា ( MATHS ÉLEM )

### ១. ការតែងខាងទស្សនវិទ្យា (៣ ម៉ោង)

**1er sujet.**— La place si élevée que l'homme occupe sur l'échelle animale, lui permet - elle d'arriver à la connaissance de la vérité.

Quel est le souverain bien de cette vérité ?

**2e sujet.**— Avantages et dangers d'une culture mathématique.

**3e sujet.**— « En tant que les théorèmes des mathématiques se réfèrent à la réalité ils ne sont pas exacts. En tant qu'ils sont exacts, ils ne se réfèrent pas à la réalité» (EINSTEIN).

### ២. រូបវិទ្យា (៤ ម៉ោង)

*Questions de cours (au choix des candidats)*

**1er sujet.**— Théorème de l'énergie cinétique. Applications.

**2e sujet.**— Pendule pesant : étude expérimentale.

Calcul de la période.

**3e sujet.**— Lois relatives aux déterminations des masses moléculaires: Loi d'Avogadro - Ampère, lois de Raoult. Densité d'un gaz par rapport à l'air, densité d'un liquide vaporisable, cryoscopie.

*Problème obligatoire*

L'analyse de 0, 290 gr d'une substance organique S composée uniquement de carbone, d'hydrogène et d'oxygène, a donné les résultats suivants:

La masse du tube à ponce sulfurique a augmenté de 0,270 gr ;

La masse des tubes à potasse a augmenté de 0, 660 gr ;

D'autre part, 0, 15 gr de ce même corps S, opéré par la méthode de Meyer, permet de recueillir 62, 4 cm $^3$ d'air mesurés sur la cuve à eau à 17°C, sous la pression de 752 mm de mercure. La tension de la vapeur saturante d'eau est f=15 mm de mercure à 17° C; le litre d'air , dans les conditions normales de pression et de température ( 0°C, 760 mm de mercure), est $a_0$=1, 293 gr.

On demande de calculer :

1° — La composition centésimale du corps S;

2° — Sa densité de vapeur et sa masse moléculaire;

3° — Sa formule brute et les isomères possibles de S, en supposant les 2 atomes de carbone voisins unis entre eux par une seule liaison;

4° — Un de ces isomères est un réducteur. Dire quelles sont les propriétés chimiques caractéristiques permettant de l'identifier.

On donne : $C = 12$
$H = 1$
$O = 16$

## ៣. គណិតវិទ្យា ( ៤ ម៉ោង )

*Questions de cours (au choix des candidats)*

**1er sujet.**— Progression géométrique : définition, expression de la somme, limite quand le nombre de termes de cette somme augmente infiniment. :

**2e sujet.**— Divisibilité d'un polynôme $P(x)$ par $x - a$.

**3e sujet.**— Résolution de l'équation :

$a \cos x + b \sin x = c$.

Relation entre a, b, c, pour que l'équation admette des solutions.

*Problème obligatoire*

On considère la fonction $y = f(x)$ définie de la façon suivante: $y = x(x - 210\, gx)$ pour $x > o$ ; $y = o$ pour $x = o$.

1°— Calculer la limite de y quand x tend vers o. En déduire que la fonction est continue $[o, +\infty[$

2° — Calculer la dérivée de la fonction y.

Désignant cette dérivée par z, étudier les variations de la fonction z. Construire le graphe de cette fonction.

3°— Etudier les variations de la fonction y; construire le graphe de cette fonction. On désigne par (Γ) la courbe de y.

4°— Etudier suivant les valeurs de m, le nombre de tangentes à la courbe (Γ) ayant pour coefficient angulaire m.

5°— On considère $F(x)$ définie de la façon suivante :

$$F(x) = \frac{x^3}{3} + \frac{x^2}{2}(1 - 2 \log x) \text{ pour } x > o \; ; \; F(o) = o$$

Démontrer que $F(x)$ est une primitive de $f(x)$.

Application au calcul de l'aire, S, du domaine limité par le segment de droite OA et l'arc OA de la courbe (Γ), où A est le point de la courbe d'abscisse 2.

(NB.— $\log x$ = logarithme népérien de x).

## ៤. វិទ្យាសាស្ត្រធម្មជាតិ (២ម៉ោង)

1er sujet.— Propriétés des muscles striés.
Etude graphique de la contraction musculaire.

2è sujet.— Mécanisme optique de la vision : formation des images et mise au point des images.

3è sujet.— Absorption intestinale et fonction glycogénique du foie.

★

## គ. ផ្នែកវិទ្យាសាស្ត្រពិសោធ (SCIENCES EXP)

## ១. ការតែងខាងទស្សនវិជ្ជា (៣ម៉ោង)

1er sujet.— « On expérimente avec sa raison »
( CLAUDE BERNARD )

2è sujet.— Un fait, une loi, une théorie. Définir brièvement le sens de ces trois termes selon qu'ils sont employés en logique ou en morale

3è sujet.— La philosophie est - elle pour le penseur « un refuge » loin du tumulte de la vie ou doit - elle être regardée comme une méditation des problèmes posés par l'actualité ?

## ២. រូបវិទ្យា (៤ម៉ោង)

*Questions de cours ( au choix des candidats )*

1er sujet.— L'aldéhyde acétique : Préparations et propriétés chimiques.

2è sujet.— L'acétamide: propriétés chimiques et préparations.

3è sujet.— Energie cinétique: Théorème ; applications au solide en mouvement de translation et de rotation autour de son axe. Applications.

***Problème obligatoire :***

Un volant dont la masse est $M = 500$ kg et peut être considérée comme entièrement répartie sur toute sa périphérie, a un diamètre de 2 mètres. Il tourne autour de son axe horizontal avec une vitesse constante de 50 tours à la minute.

On demande de calculer :

1°— l'accélération de son mouvement ;

2°— son énergie cinétique en joules et la quantité de chaleur, en calories, développée au cours de l'arrêt du volant sous l'action d'un frein agissant par frottement ;

3°— quelle serait la masse d'un projectile dont la vitesse est de 30 m/s, pour que son arrêt brusque puisse dégager la même quantité de chaleur, et par suite posséder l'énergie cinétique précédemment calculée ?

4°— un treuil de masse négligeable, de rayon $r = 20$ cm, de même axe que celui du volant, est solidaire à ce dernier. La volant peut être mis en mouvement par une masse $m = 100$ kg attachée à un fil inextensible passant sur ce treuil. Le système étant au repos, et on agit sur m qui descend d'une hauteur $h = 1$m.

Quelle est alors la vitesse de m ?

On prendra :

$J = 4,2$ J/cal. ;

$g = 9,80$ M.K.S. ;

$\pi^2 = 9,9$ ;

On négligera les forces de frottement.

## ៣. គណិតវិទ្យា (៣ម៉ោង)

1.— Etudier la fonction : $y = x - 1 + \frac{9}{x}$

Construire la courbe représentative.

Calculer l'aire de la surface comprise entre la courbe, l'assymptote oblique et les droites d'équation $x = 1$ et $x = e$.

On prendra $e = 2,7$.

2.— Soit une progression arithmétique de 7 termes $u_1$, $u_2$, $u_3$, $u_4$, $u_5$ $u_6$, $u_7$

On pose $u_4 = a$.

a)- Calculer en fonction de a la raison r de la progression arithmétique sachant que :

$(u_1 + u_2 + u_3)(u_5 + u_6 + u_7) = 9r(1-4)$.

Déterminer la somme des 7 termes.

b)- Vérier la formule :

$$\frac{u_3 u_6 - u_2 u_5}{2u_4} = r.$$

3.— Dans une loterie de 70 billets, il y a 6 lots.
On prend 3 billets.
Quelle est la probabilité :
a)— de gagner un lot et un seul.
b)— de ne rien gagner.

## ៤. វិទ្យាសាស្ត្រធម្មជាតិ (៣ម៉ោង)

1[er] sujet.— Température du corps ; la régulation thermique.

2[è] sujet.— Description sommaire de l'appareil urinaire ; physiologie de l'élimination urinaire.

3[è] sujet.— Le pancréas et ses fonctions.

✻


បណ្ណាគារ គីម គី

លេខ 95 វិថីព្រះយុគន្ធរ ភ្នំពេញ

បណ្ណាគារ គិម សេង

លេខ 223 មហាវិថី ព្រះមុនីវង្ស ភ្នំពេញ

មានសេចក្ដីរីករាយនឹងចុះថ្លៃ 20 % ជូនសមាជិកនៃ សមាគមសាស្ត្រាចារ្យខ្មែរ ដែលទៅទិញសៀវភៅខ្មែរនៅបណ្ណាគារទាំងនេះ ។

សូមបង្ហាញបណ្ណសមាជិក !



# អត្ថបទ & ឯកសារ

## ប្រវត្តិវិទ្យា

## ការប្រកួតប្រជែងអន្តរជាតិ ពីឆ្នាំ 1904 ដល់ឆ្នាំ 1914

### សេចក្ដីផ្ដើម

ដោយ ម៉ៃ លង់

ឆ្នាំ ១៩០៤ – ១៩០៥ ជាឆ្នាំដែលប្រទេសបារាំងនិងចក្រភពអង់គ្លេសបានចិត្តចូលជិតគ្នា ជាឆ្នាំដែលប្រទេសរុស្ស៊ីត្រូវទទួលបរាជ័យមួយយ៉ាងជូរចត់ក្នុងចម្បាំងជប៉ុន - រុស្ស៊ី នៅម៉ង់ជូរី ជាឆ្នាំដែលធ្វើឲ្យនយោបាយនៅទ្វីបអឺរ៉ុប ឈានចូលក្នុងទំព័រប្រវត្តិសាស្ត្រថ្មីមួយទៀត ជាឆ្នាំដែលប្រកបទៅដោយវិបត្តិផ្សេងៗ ទៅដោយស្ថានការតឹងតែងជាលំដាប់ ។

### ក. មហាអំណាចទ្វីបអឺរ៉ុប

មកដល់ឆ្នាំ ១៩១៤ នៅទ្វីបអឺរ៉ុប មានរដ្ឋតែ ៥ ទេ ដែលជាមហាអំណាចក្នុងលោកយើងនេះ ហើយមហាអំណាចទាំងនោះ ជាអ្នកដឹកនាំនយោបាយសាកលលោកទាំងមូលតែម្ដងៗ ប៉ុន្តែមហាអំណាចទាំង ៥ ខាងលើនេះ មានការលូតលាស់មិនស្មើគ្នាឡើយ ។

១. ប្រទេសរុស្ស៊ីនិងអូទ្រីស-ហុងគ្រី — ប្រទេសទាំងពីរនេះ ទើបតែចាប់ផ្ដើមរៀបចំសេដ្ឋកិច្ចរបស់ខ្លួនឲ្យទាន់សម័យ ឲ្យមានលក្ខណៈជាសេដ្ឋកិច្ចរបៀបទំនើបៗ ឧស្សាហកម្មមានសភាពអន់ថយនៅឡើយ ។ រោងចក្រមានតិចតួចស្ដួចស្ដើងតាមទីក្រុង

ទាំងឡាយ ។ ផ្លូវថេភ្លើងកំពុស្លូវល្អគួរលាស់ ហើយភាគច្រើននៃប្រជាពលរដ្ឋ ជាអ្នកស្រែចំការ ប្រកបមុខរបរកសិកម្ម ។

២. សាធារណរដ្ឋបារាំង ជាប្រទេសប្រកបដោយឧស្សាហកម្មទំនើប ហើយមានមធ្យោបាយដឹកនាំល្អគួរលាស់យ៉ាងក្រៃលែង ។ កសិកម្មមានការវិវត្តយឺតយ៉ាវ ។ កសិកម្មបែបទំនើបក៏កំពុស្លូវមានដែរ ។ តែសាធារណរដ្ឋបារាំង ជាមហាអំណាចអាណានិគមមួយខ្លាំងពូកែ មានទឹកដីឯនាយសមុទ្រច្រើន ភាយប៉ាយគ្រប់ទ្វីប ។ ប្រាក់បារាំងទៀតសោត មានដំហររឹងប៉ឹង ទុកជារូបិយប័ណ្ណអន្តរជាតិ ដូចប្រាក់ដុល្លាសព្វថ្ងៃនេះ ។

៣. បក្រភពអង់គ្លេស ជាមហាអំណាចអាណានិគមមួយ មានចក្ខុទានុភាពខ្លាំងណាស់ ។ មកទល់នឹងដើមសតវត្សទី ២០ បក្រកតពអង់គ្លេស ជាមហាអំណាចលេខ១ ខាងសេដ្ឋកិច្ច នៅក្នុងទ្វីបអឺរ៉ុប ។ ការបដិវត្តន៍ខាងសេដ្ឋកិច្ច បានប្រព្រឹត្តនៅបក្រកតពអង់គ្លេសមុនគេបង្អស់ គឺចាប់តាំងពីដើមសតវត្សទី ១៩ មកម៉្លេះ ។ ម៉្លោះហើយបក្រកតពអង់គ្លេសមានឧស្សាហកម្មល្អគួរលាស់ជាងគេ (មានឧស្សាហកម្មធុនច្រើន—ត្បាញ—ដែកថែបលេខ ១ ក្នុងលោក) ។

ម្យ៉ាងទៀត បក្រកតពអង់គ្លេសមានប្រទេសជារណបធំជាងគេ ( ៣១ លានគីឡូម៉ែត្រក្រឡា-៣០០ លាននាក់) គឺ១ភាគ ៤ នៃមនុស្សក្នុងលោកយើងទាំងមូល ។ ប៉ុន្តែមកដល់ឆ្នាំ ១៩១៤ មហាអំណាចបក្រកតពអង់គ្លេស ត្រូវមានគេកំហែងគំរាមដំហរបស់ខ្លួន គឺអាល្លឺម៉ាញ ។

៤. អាល្លឺម៉ាញ ក្នុងដើមសតវត្សទី ២០ ប្រទេសអាល្លឺម៉ង់ជាប្រទេសមួយ ដែលមានប្រជាពលរដ្ឋច្រើនជាងគេ នៅអឺរ៉ុបប៉ែកខាងលិច (៦៧ លាននាក់) ។ ជាប្រទេសប្រកបដោយគោគទ្រព្យធនធានច្រើន ។ ឧស្សាហកម្មអាល្លឺម៉ង់ល្អគួរលាស់យ៉ាងឆាប់រហ័សក្រៃលែង ។ ពាណិជ្ជកម្ម នឹងឧស្សាហកម្មអាល្លឺម៉ង់តែងតែប្រកួតប្រជែង នឹងឧស្សាហកម្ម

នឹងពាណិជ្ជកម្មអង់គ្លេស ហើយច្រើនតែទទួលជោគជ័យទៀតផង ។ ប្រទេសអាល្លឺម៉ង់ជាប្រទេសមានកងទ័ពច្រើនជាងគេ ប្រកបដោយអាវុធយុទ្ធភណ្ឌយ៉ាងទំនើប ហើយមាននាយដឹកនាំនិងវិន័យយ៉ាងហ្មត់ចត់ ។ ប្រទេសអាល្លឺម៉ង់ចង់ត្រួតត្រាសមុទ្រថែមទៀត ។ នាវាអាល្លឺម៉ង់ជានាវាទីពីរក្នុងលោក បន្ទាប់ពីចក្រភពអង់គ្លេស ដែលជាហេតុធ្វើឲ្យចក្រភពអង់គ្លេស មានសេចក្ដីព្រួយបារម្ភជាច្រើន ។

## ខ. ការប្រណាំងប្រជែងខាងសេដ្ឋកិច្ច

ដូចយើងបានឃើញត្រួសៗមកខាងលើ មហាអំណាចទាំង ៥ ខំពង្រឹងហើយពង្រីកឧស្សាហកម្មតែរៀងៗខ្លួន ។ ទាំងអស់គ្នា គេខំធ្វើឲ្យឧស្សាហកម្មលូតលាស់ឆាប់រហ័សទាន់សម័យ ដើម្បីយកឈ្នះតែសត្រូវខ្លួន ។ នៅប្រទេសអាល្លឺម៉ង់ ការលូតលាស់មានសន្ទុះលឿនណាស់ ដែលជាហេតុនាំឲ្យមហាអំណាចឯទៀត ព្រួយបារម្ភជានិច្ច ។ ការប្រណាំងប្រជែងរវាងមហាអំណាចទាំងនេះ មានសភាពរឹតតែស្វិតស្វាញឡើងៗ ។ ក្នុងពិភពលោកយើងទាំងមូល គេប្រកួតប្រណាំងដណ្ដើមផ្សារគ្នា ដណ្ដើមសម្បទានអណ្ដូងរ៉ែ ឬផ្លូវរទេះភ្លើង ។ គេប្រណាំងគ្នា ដណ្ដើមទទួលធ្វើការសាធារណៈឲ្យប្រទេសណាដែលត្រូវការ គេដណ្ដើមគ្នាលក់អាវុធយុទ្ធភណ្ឌទៅដល់ប្រទេសនានា ។ល។

ជួនកាល រដ្ឋាភិបាលជួយការពារផលប្រយោជន៍ជនជាតិរបស់គេ ក្នុងការប្រកួតប្រណាំងដណ្ដើមគ្នានេះ ដែលជាហេតុនាំឲ្យការប្រណាំងប្រជែងខាងសេដ្ឋកិច្ច ប្រែក្លាយទៅជាការប្រណាំងប្រជែងខាងនយោបាយទៀតផង ។

## គ. ការប្រណាំងប្រជែងខាងអាណានិគម

នៅដំណាច់សតវត្សទី ១៩ សាកលលោកទាំងមូលត្រូវបានបែងចែកជាស្រេច រវាងមហាអំណាចអង់គ្លេស បារាំង រុស្ស៊ី អាល្លឺម៉ាញ អ៊ីតាលី សហរដ្ឋអាមេរិក ។ ប្រទេស

អាល្លឺម៉ាញ បានចំណែកតិចជាងគេ គឺតិចជាងចក្រភពអង់គ្លេស នឹងសាធារណរដ្ឋបារាំង ។ ចក្រភពអង់គ្លេស ត្រូវបានទទួលចំណែកធំជាងគេខាងអាណានិគម ។ ប្រទេសអង់គ្លេសជាប្រទេសលេខ ១ ក្នុងលោក ក្នុងវិស័យពាណិជ្ជកម្ម ហើយនឹងការដឹកមូលធនចេញទៅរកស៊ីនៅក្រៅប្រទេស ។ ក្នុងករណីនេះ ប្រទេសអាល្លឺម៉ាញ ដែលមានគំនិតចង់សើរើបែងចែកពិភពលោកម្តងទៀត មុខតែប្រទះនឹងឧបសគ្គមួយយ៉ាងសំបើម គឺចក្រភពអង់គ្លេសនេះឯង ។

នៅដើមសតវត្សទី ២០ ទំនាស់រវាងមហាអំណាចអាណានិគមទាំងឡាយ មានសភាពរឹតតែខ្លាំងឡើង ៗ ។ យ៉ាងណាមិញ ការលូតលាស់យ៉ាងឆាប់រហ័សនៃឧស្សាហកម្ម បានបង្កើតឲ្យមានចក្រពត្តិនិយម ពោលគឺនយោបាយរុករានយកប្រទេសដទៃមកធ្វើជាអាណានិគមរបស់ខ្លួន ។

ក្នុងករណីនេះ ប្រទេសអង់គ្លេសដែលមានអារ្យធម៌ខាងឧស្សាហកម្មមុនគេ ដណ្ដើមបានប្រទេសអាណានិគមច្រើនជាងគេដែរ ក្នុងលោកយើងនេះ ហើយចក្រភពអង់គ្លេសត្រូវតែយាមល្បាតអាណានិគមរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវគោលការណ៍នយោបាយពីរយ៉ាង គឺ ម្យ៉ាងរក្សាឧត្តមភាពលើសមុទ្រ នឹងមហាសាគរទាំងឡាយ ម្យ៉ាងទៀតគឺពិនិត្យត្រួតត្រាផ្លូវឆ្ពោះទៅកាន់ប្រទេសឥណ្ឌា ។

ចំណែកប្រទេសបារាំង គេបង្ហើយការស្ថាបនាអាណានិគមរបស់គេ នៅទ្វីបអាហ្វ្រិកដោយភ្ជាប់ប្រទេសម៉ារ៉ុកឲ្យចូលមកក្នុងអំណាចរបស់គេ ។ ប្រទេស អ៊ីតាលីដែលត្រូវគេទាត់ចេញពីប្រទេស ទុយនីស៊ីនឹងប្រទេស អេស្យូពី (Ethiopie) បានវាតយកប្រទេសទ្រីប៉ូលីតែន (Tripolitaine) ហើយបានគ្រប់គ្រងលើផ្លូវសមុទ្រ អាទ្រីយ៉ាទិក (Mer Adriatique) ឆ្នេរសមុទ្រប៉ែកបស្ចិមនៃដំបន់បាល់កង់ ។

ម្យ៉ាងទៀត ទៀបកោះបាល់កង់ (Presqu'île balkanique) ជាដំបន់មួយគ្មានស្ថិរភាពបន្តិចណាឡើយ ហើយជាដំបន់ដែលប្រទេសរុស្ស៊ី នឹងប្រទេសអូទ្រីសរកឥទ្ធិពលរបស់ខ្លួន ។

ប្រទេសរុស្ស៊ីដែលបានទទួលបរាជ័យយ៉ាងដួលបាក់នៅចុងបូព៌ាប្រទេស ក្នុងចម្បាំងរុស្ស៊ី – ជប៉ុន (១៩០៥) បានត្រឡប់មករកគោលដៅចាស់របស់ខ្លួនវិញ គឺរកយកទីក្រុងកុងស្តង់ទីណូប ( Constantinople ) និងច្រកសមុទ្រដេត្រូ (les Détroits) ។

ប្រទេសអូទ្រីសចង់ដណ្តើមយកប្រទេស សាឡូនិក ( Salonique ) ហើយនឹងគ្រប់គ្រងលើប្រទេស សែប៊ី (Serbie) ដែលបាំងផ្លូវខ្លួន ។ នេះជាបញ្ហាស្មុគ្រស្មាញមួយ ពីព្រោះនៅក្នុងប្រទេសអូទ្រីសមានជនជាតិ យូហ្គោស្លាវ រាប់លាននាក់ដែលនិយមក្រឡេកសម្លឹងតែប្រទេសសែប៊ី ( Serbie ) ជារដ្ឋសេរី ។

ចំណែកប្រទេសអាល្លឺម៉ង់វិញ មិនត្រឹមជាមហាអំណាចលើទ្វីបប៉ុណ្ណោះទេ គឺចង់បានជាមហាអំណាចលើសមុទ្រ និងលើពិភពលោកយើងទាំងមូលថែមទៀត ។ ដោយគ្មានដីសេសសល់នឹងត្រួតត្រា មហាអំណាចអាល្លឺម៉ង់ បានសម្លឹងរមិលមើលគ្រប់ទិសទី គឺសម្លឹងមើលប្រទេសទួរគីភាគអាស៊ី តែក្នុងដំបន់នោះ ឧបសគ្គបានរង់ចាំខ្លួនជាស្រេច គឺចក្រភពអង់គ្លេសនិងប្រទេសរុស្ស៊ី សម្លឹងលើប្រទេសម៉ារ៉ុក តែត្រូវពារលើសាធារណរដ្ឋបារាំង សម្លឹងលើប្រទេសអាហ្វ្រិកប៉ែកសុរិយាវិថី តែត្រូវតែបណ្តេញអ្នកត្រួតត្រានៅទីនោះដោយបឋម គឺប្រទេសបែលស៊ិក និងប្រទេសពរទុយហ្គាល (Belgique - Portugal) ។

ចក្រពត្តិនិយមអាល្លឺម៉ង់ ជាចក្រពត្តិមួយដែលមានកម្មវិធីសាំញ៉ាំពុំច្បាស់លាស់ឡើយ តែមានមូលដ្ឋានសេដ្ឋកិច្ចខ្លាំងជាងគេ ហើយមានកងទ័ពសាហាវទៀតផង ។

ដូចនេះហើយបានជា តាំងពីឆ្នាំ ១៩០៤ ដល់ឆ្នាំ ១៩១៤ ទ្វីបអឺរ៉ុបទាំងមូលបានរស់ក្នុងការកំហែងគំរាមនៃចម្បាំងជានិរន្តរ៍ ។ វិបត្តិមួយហើយមួយទៀត ដែលបានកើតឡើងដោយបញ្ហាម៉ារ៉ុក និងបញ្ហាបាល់កង់ បានធ្វើឲ្យសង្គ្រាមសាកលលោកហៀបតែនឹងផ្ទុះជាច្រើនលើក ។

ព្រឹត្តិការណ៍សំខាន់ៗ ក្នុងរយៈសម័យនេះមានដូចតទៅ :

ការឡើងគោកនៃចក្រពត្រាធិរាជអាល្លឺម៉ង់ ហ្គីយ៉ូមទី២ (Guillaume II) ក្នុងឆ្នាំ១៩០៥ បានបើកឲ្យមានវិបត្តិជាលើកដំបូងមួយ គឺវិបត្តិអំពីបញ្ហាម៉ារ៉ុក ។ សន្និសីទនៅទីក្រុងអាល់ហ្សេស៊ីរ៉ាស ឆ្នាំ១៩០៥ បានដោះស្រាយឲ្យបាកផុតពីវិបត្តិនេះ ដែលជាហេតុនាំឲ្យមានសេចក្តីព្រមព្រៀងរវាងប្រទេសអង់គ្លេស នឹងប្រទេសរុស្ស៊ី ( ឆ្នាំ ១៩០៧ ) ហើយនឹងការស្ថាបនានូវសម្ពន្ធត្រីភាគីមួយ ។

ក្រោយមក មានវិបត្តិមួយទៀតបានកើតឡើងនៅទៀបកោះបាល់កង់ដោយប្រទេសអូទ្រីសភ្ជាប់ចូលក្នុងប្រទេសខ្លួននូវប្រទេស បុស្សនី-ហ៊ែហ្សេហ្គូវីន (Bosnic Herzégovine) ក្នុងឆ្នាំ ១៩០៨ ។

ក្នុងឆ្នាំ ១៩១១ កងទ័ពបារាំងបានលុកចូលក្នុងទីក្រុងហ្វេស ដែលជាហេតុនាំឲ្យប្រទេសអាល្លឺម៉ង់ បញ្ជូននាវាចម្បាំងរបស់ខ្លួនមកចតចំមុខផែអាហ្គាឌៀរ ដើម្បីគំហែងគំរាមបារាំង ។ វិបត្តិទី ២ អំពីបញ្ហាម៉ារ៉ុកនេះ ត្រូវបានដោះស្រាយដោយការព្រមព្រៀងរវាងប្រ-ទេសបារាំងនឹងប្រទេសអាល្លឺម៉ង់ ស្តីពីបញ្ហាម៉ារ៉ុកនឹងបញ្ហាកុងហ្គោ ។

ក្រោយមកទៀត មិនយូរប៉ុន្មាន មានការស្មុគ្រស្មាញមួយបានកើតឡើងនៅភូមិភាគមជ្ឈិម :— ប្រទេសអ៊ីតាលី បានចូលត្រួតត្រាលើប្រទេសទ្រីប៉ូលីតែន ( ឆ្នាំ១៩១១) ចម្បាំងរវាងប្រទេសអ៊ីតាលីនឹងប្រទេសទួរគី ( ១៩១១ - ១៩១២ ) សម្ពន្ធនៃប្រទេសបាល់កង់ច្បាំងនឹងប្រទេសទួរគី ( ១៩១២ - ១៩១៣ ) ច្បាំងនឹងប្រទេសប៊ុលហ្គារី (១៩១៣) ។ ការពង្រីកនៃប្រទេសស៊ែរប៊ី - ប្រទេសក្រិច ប្រទេសរូម៉ានី ទាំងនេះគឺជាហេតុការណ៍មួយដែលប្រទេសអូទ្រីសមិនអាចអត់ធ្មត់បានឡើយ ។

# វេយ្យាករណ៍

## សេចក្ដីសង្កេតអំពីស្រៈខ្មែរ ដែលមានរៀបរាប់ក្នុងសៀវភៅវេយ្យាករណ៍ផ្សេងៗ

ញ៉ុប ម៉ៅ

ដោយបានអានសៀវភៅវេយ្យាករណ៍ខ្លះ ដែលមានសព្វថ្ងៃនេះ ខ្ញុំបានសង្កេតឃើញថាពុំមានឯកភាពឡើយ ចំពោះការរៀបរាប់អំពីស្រៈខ្មែរយើង ។ ខ្ញុំបានកត់សំគាល់សភាពប្លែកៗ គ្នាដូចតទៅនេះ :

### ១. អំពីប្រភេទវិភាគនៃស្រៈ

ក) តាមសៀវភៅវេយ្យាករណ៍របស់លោក អៀវ កើស មិនបានបញ្ជាក់ថាមានប៉ុន្មានពួកឲ្យបា្រស់លាស់ទេ ។

ខ) តាមវេយ្យាករណ៍ពិសេសថាមាន ២ ពួកគឺ :

— និស្ស័យសរៈ (ស្រៈមិនពេញតួ)

— និស្សិតសរៈ (ស្រៈពេញតួ) ។

គ) តាមកម្ពុជវេយ្យាករណ៍ថាមាន ៣ ពួកគឺ :

— ស្រៈពេញតួ

— ស្រៈនិស្ស័យ

— ស្រៈផ្សំ

### ២. អំពីចំនួនស្រៈ

ក) តាមវេយ្យាករណ៍លោក អៀវ កើស មាន ២១ អក្ខរ ហើយបើគិតតាមសម្លេងត្រូវមានរហូតដល់ ៤២ អក្ខរ ។

ខ) តាមកម្ពុជវេយ្យាករណ៍ថា :

– ស្រៈពេញតួមាន ១៨ តួ

– ស្រៈនិស្ស័យមាន ២១ តួ

– ស្រៈផ្សំមាន ៦ តួ ។

គ) តាមវេយ្យាករណ៍ពិសេសថា :

– ស្រៈនិស្ស័យមាន ២១ តួ

– ស្រៈពេញតួមាន ១៤ តួ ។

ឃ) តាមវេយ្យាករណ៍លោក ពូវ អ៊ុមថា :

– ស្រៈពេញតួមាន ១៥ តួ

– ស្រៈនិស្ស័យមាន ២០ តួ ។

ង) តាមវេយ្យាករណ៍លោក សៀង ច័នឌីថា :

– ស្រៈពេញតួមាន ១៤ តួ

– ស្រៈនិស្ស័យមាន ២០ តួ ។

ច) តាមវចនានុក្រមថា :

– ស្រៈនិស្ស័យមាន ២១ តួ

– ស្រៈពេញតួ មាន ១៥ តួ ។

## ៣. អំពីរូបរាងនៃស្រៈពេញតួ :

ក) តាមវេយ្យាករណ៍លោក អៀវ កើស មានដូចតទៅនេះ !

– អ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ អេ

អែ អៃ អោ អៅ អុំ អំ អាំ អះ ។

– មានស្រៈពេញតួខាងលើនេះខ្វះអាចមានរូបរាងដូចតទៅ :

ឥ ឦ ឧ ឩ ឯ ឰ ឱ ឳ ដោយបន្ថែមស្រៈ ឫ ឬ ឭ ឮ ។

ខ) តាមវចនានុក្រមថា ប៉ុកពីវេយ្យាករណ៍ លោក អៀវ កើស តែគ្រប់ស្រៈខ្វះ ដូចតទៅ :

ឥ ឦ ឧ ឩ ឯ ឰ ឱ ឳ + ឫ ឬ ឭ ឮ ឳ

គ) តាមវេយ្យាករណ៍ពិសេសមានដូចតទៅនេះ :

អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ ។

ឃ) តាមកម្ពុជវេយ្យាករណ៍ថាមានដូចតទៅ :

អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ អុំ អំ អាំ អះ ។

## ៤. អំពីសម្លេងវែង–ខ្លីនៃស្រៈ

ក) តាមវេយ្យាករណ៍លោក អៀវ កើស ថា :

– ស្រៈខ្លីមាន ១០ តួគឺៈ អិ អី អឹ អុ អៃ អៅ អុំ អំ អាំ អះ ។

– ស្រៈវែងមាន ១១ តួ គឺៈ អ អា (អ៊ី) អឺ អូ អួ អើ អឿ អៀ អេ អែ អោ ។

ខ) តាមវេយ្យាករណ៍ពិសេសថា :

– ស្រៈខ្លីមាន ៤ តួ គឺៈ | ិ ឹ ុ

– ស្រៈវែងមាន : ា ី ឺ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ។

គ) តាមលោក ញ៉ុក ថែម ថា :

– ស្រៈខ្លីមាន ៦ តួ គឺ : | ិ ឹ ុ េះ ោះ |ះ ។

– ស្រៈវែងមាន ១៧ តួ គឺ : ា ី ឺ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំះ ។

## ៥. អំពីស្រៈសុទ្ធនឹងស្រៈផ្សំ :

ក) តាមវេយ្យាករណ៍លោក អៀវ កើសថា :

– ស្រៈសុទ្ធគឺ : អ អា អិ អី អុ អូ (៦ តួ)

– ស្រៈផ្សំគឺ : អឹ អួ អៀ អែ អៅ (៥ តួ)

ខ) តាមលោក ញ៉ុក ថែម :

– ស្រៈសុទ្ធ លោកមិនបានបញ្ជាក់ទេ

– ស្រៈផ្សំ គឺ : អឹ + យ = ៀ

អា + វ = អៅ

អុ + វ = អួ ។

## ៦. អំពីការរៀបចំស្រៈ

ក) តាមវេយ្យាករណ៍លោក អៀវ កើស នឹងកម្ពុជវេយ្យាករណ៍ដាក់ស្រៈ ឱ បន្ទាប់ស្រៈ ឲ

ខ) តាមវេយ្យាករណ៍លោក ពូវ អ៊ុម ដាក់ស្រៈ ឱ បន្ទាប់ស្រៈ ឳ ។

យើងតែងចងចាំទុកថា : "វេយ្យាករណ៍ខ្មែរជាក្បួនបង្រៀនវិធីអក្ខរៈ ដើម្បីនិយាយត្រឹមត្រូវ សរសេរត្រឹមត្រូវក្នុងភាសាខ្មែរ" ។ ចុះបើឥឡូវមានសៀវភៅវេយ្យាករណ៍ប្លែកៗគ្នាយ៉ាងនេះទៅហើយ តើយើងអាចនិយាយ សរសេរត្រឹមត្រូវបានឬទេ ?

ហេតុដូច្នេះ ក្នុងសម័យដែលយើងកំពុងក្រាក់រលឹក ចាប់រៀបចំភាសាជាតិជាថ្មីឡើងវិញនេះ ជាបឋមគួរតែយើងនាំគ្នាតែងវេយ្យាករណ៍ឲ្យបានត្រឹមត្រូវ ប្រកបដោយវិចារណញ្ញាណសិន នោះទើបការរៀបចំភាសាមានឯកភាពល្អ ។

អត្ថបទអនុពាក្យ

## បញ្ហានៃការបង្កើតពាក្យថ្មី

ភាសាណាក៏ដោយ ក៏ត្រូវចោទនឹងដោះស្រាយបញ្ហានៃការបង្កើតពាក្យថ្មីនេះដែរ ពីព្រោះភាសាតែងតែផ្លាស់ប្ដូរទៅតាមការផ្លាស់ប្ដូរចំរើនលូតលាស់ នៃសង្គមមនុស្ស ។

ជីវភាព គ្រឿងប្រដាប់ប្រើប្រាស់ វិទ្យាសាស្ត្រ តិចនិក សេដ្ឋកិច្ច ការរៀបចំសង្គម ការប្រស័យទាក់ទងរវាងជាតិនានា ពោលគឺវប្បធម៌នឹងសង្គមធម៌ទាំងមូលតែងតែមានប្រវត្តិផ្លាស់ប្ដូរបង្កបង្កើតនូវសភាពលក្ខណៈថ្មីៗពុំចេះអស់ពុំចេះហើយសោះឡើយ ។ ដូច្នេះភាសាត្រូវបង្កើតពាក្យថ្មីៗ ដើម្បីសំគាល់នូវសភាពថ្មីៗក្នុងប្រវត្តិផ្លាស់ប្ដូរនៃសង្គមមនុស្ស ចាប់តាំងអំពីកំណើតនៃភាសាហូរហែទៅតាមដំណើរសង្គមមនុស្សនេះឯង ។

ម្យ៉ាងវិញទៀត ដំណើរផ្លាស់ប្ដូរនៃភាសាពុំមែនចេះតែប្រព្រឹត្តទៅ ដោយឥតលំនាំឥតវិធីអ្វីសោះក៏ទេដែរ ប៉ុន្តែឋិតនៅលើមូលភាពនឹងធម៌ភាពរបស់ភាសាដ៏ច្បាស់លាស់ ។ ឯការពុំគោរពនូវសភាពនឹងលំនាំនៃភាសាខ្មែរក៏បានប្រព្រឹត្តឡើងដែរ ជាហេតុនាំឲ្យមានការបង្កើតពាក្យថ្មីច្រើនបែបយ៉ាង ម្តងបែបនេះ ម្តងបែបនោះ ហើយទើសទាស់គ្នាថែមទៀត ។

នេះហើយគឺជាបញ្ហានៃការបង្កើតពាក្យថ្មីដែលមានចោទឡើងសព្វថ្ងៃនេះ ចំពោះភាសាខ្មែរ ។

កេង វ៉ាន់ សាក់

អត្ថបទជ្រើសរើស

(មូលភាពនៃការបង្កើតពាក្យថ្មី)

ដោយ ញឹប ម៉ៅ

យើងទើបនឹងទទួលជាចុងក្រោយបំផុតនូវដំណឹងអំពី អាពាហ៍ពិពាហ៍របស់ :

– មិត្ត ឈួន ឆយិទ្រី នឹងកញ្ញា ឈឿន វួចគ្រុយ

– មិត្ត ឯក សំអុល " ម៉ក់ ចុងឡេង

– មិត្ត ជាម ងួនលី " សេង សីម៉ា ។

សូមប្រសិទ្ធិពរ ឲ្យគូទាំងបីនេះ បានជួបតែនឹងសុកមង្គលវិបុលសុខកុំបីឃ្លៀងឃ្លាតឡើយ ។


**ខេមរបណ្ណាគារ**

លេខ 174 វិថីខេមរភូមិន្ទ ភ្នំពេញ

មានសេចក្ដីរីករាយនឹងចុះថ្លៃ 15 % បំពោះសៀវភៅខ្មែរ ជូនដល់មិត្តណាដែលទៅទិញសៀវភៅខ្មែរនៅបណ្ណាគារនេះ ហើយដែលបានបង្ហាញបណ្ណសមាជិក !




លេខ ៦៩ វិថីខេមរភូមិន្ទ ភ្នំពេញ

បើមិត្តសមាជិក ស. ស. ១. កាន់ប័ណ្ណ សមាជិកទៅទិញខោអាវនៅហាងនេះ

ហាងនេះ មានសេចក្ដីរីករាយ ហើយនឹងកិត្តិយសនឹងចុះថ្លៃជូនមិត្តយ៉ាងពេញចិត្ត ។

សូមអញ្ជើញសាកមើល !


Imp. Chamroeun Sambat
23 C, V. Samdech Pann - P.P
Tir. 1200 ex.